បោះពុម្ពផ្សព្វផ្សាយដោយ

CIUS
CAMBODIAN INSTITUTE FOR URBAN STUDIES

អភិវឌ្ឍន៍ដោយមានកិច្ចសហការជាមួយ

DGNB
Deutsche Gesellschaft für Nachhaltiges Bauen
German Sustainable Building Council

គាំទ្រជាផ្លូវការដោយ



## ឧបករណ៍បរិវត្តកម្មនៃគម្រោង B4P

# លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍

០១.០

ឧបត្ថម្ភដោយ

Federal Ministry
of Research, Technology
and Space

FONA
Research for Sustainability

SURE
Sustainable
Development
of Urban Regions

09.0

NEC

# B4P TTB GL
# លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍

## មាតិកា


I អារម្មណ៍កថា 06

II សេចក្ដីផ្ដើម 08

- » ការរួមចំណែកពីតំបន់ត្រូវអភិវឌ្ឍន៍
- » លក្ខខណ្ឌវិនិច្ឆ័យជាមួយនឹងសំណុំគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ
- » ទម្រង់នៃលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍
- » លក្ខខណ្ឌវិនិច្ឆ័យចីរភាពដំណាក់កាលដំបូង ដើម្បីការអភិវឌ្ឍន៍តំបន់ប្រកបដោយចីរភាព

III ការអនុវត្តលក្ខខណ្ឌវិនិច្ឆ័យនៃគម្រោង B4P សម្រាប់តំបន់ត្រូវអភិវឌ្ឍន៍ 10

IV លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍ 14

- » ការរចនាទីក្រុងបែបសមាហរណកម្ម (០២.១)
- » ហេដ្ឋារចនាសម្ព័ន្ធបៃតង ខៀវ (០២.២)
- » ការចល័តប្រកបដោយចីរភាព (០២.៣)
- » ការការពារអាកាសធាតុ និងលំហូរថាមពល (០២.៤)
- » បរិយាប័ន្នសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន (០២.៥)
- » អភិបាលកិច្ច និងការចូលរួម (០២.៦)

V មូលដ្ឋានគ្រឹះនៃសន្ទស្សន៍ការរៀបចំ 28

VI វិភាគទានពីដៃគូ B4P និងទំនាក់ទំនង 32

VII ឯកសារយោង 36



*Version: ១.0*
*កែសម្រួលចុងក្រោយនៅ ១៣.វិច្ឆិកា.២០២៥*

ក្រាហ្វិកនៃគម្របឯកសារ៖
Uddam Pen, Prosob Media, Phnom Penh.


០១.០
NEC

# អារម្ភកថា

សួស្តីរូបនីយករ អ្នកអភិវឌ្ឍន៍អចលនទ្រព្យ រដ្ឋបាលទីក្រុង អាជ្ញាធរជាតិ និងអ្នកពាក់ព័ន្ធក្នុងវិស័យនគរូបនីយកម្មរាជធានីភ្នំពេញ៖

តម្រូវការភូមិដ្ឋានសហគមន៍ចីរភាពរឹតតែបន្ទាន់ជាងមុន ដោយនគរូបនីយកម្មទីក្រុងកំពុងនឹងបន្តជំរុញក្នុងរាជធានីភ្នំពេញ ក៏ដូចជាទីក្រុងនៅបណ្តាខេត្តផ្សេងៗទៀតដែរ។ ការប្រឈមទៅនឹងបញ្ហានានាដូចជា បម្រែបម្រួលអាកាសធាតុ ការបាត់បង់ធន់ធានធម្មជាតិ និងអតុល្យភាពសង្គម យើងទាំងអស់គ្នាមានកាតព្វកិច្ចមិនត្រឹមតែបង្កើតបរិស្ថានទីក្រុង ដែលប្រកបដោយភាពរស់រវើក និងល្អគន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ធន់នឹងធម្មជាតិ ហើយប្រកបដោយបរិយាប័ន្នសង្គមផងដែរ។

ក្រោមការសហការជាមួយគណកម្មការអគារបៃតងប្រទេសអាល្លឺម៉ង់ (DGNB) ក្រុមពហុជំនាញរបស់យើងបានធ្វើការប្រឹងប្រែង ដើម្បីបង្កើតឡើងនូវលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍ PPCH-B4P។
កិច្ចការនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាក្របខ័ណ្ឌដ៏ទូលំទូលាយ និងអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាពក្នុងរាជធានីភ្នំពេញ។

លក្ខខណ្ឌវិនិច្ឆ័យរួមមាន សូចនាករ សម្រាប់វាយតម្លៃលក្ខណៈចីរភាពសំខាន់ៗរួមមាន៖ សមាហរណកម្មការរៀបចំគម្រោងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធបៃតង ខៀវ ការចល័តដោយ-ចីរភាព ការការពារអាកាសធាតុនិងលំហូរថាមពល បរិយាប័ន្នសង្គមនិងសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងអភិបាលកិច្ចនិងការចូលរួមផងដែរ។ ដោយផ្តោតលើចំនុចស្នូលទាំង ៦នេះ យើងសង្ឃឹមថានឹងជំរុញឲ្យការអភិវឌ្ឍន៍សហគមន៍នានា (ពីដំណាក់កាលធ្វើផែនការដំបូងទៅដល់ការអនុវត្ត) មានការគិតទៅលើសុខុមាលភាព និងសេចក្តីសុខនៃសហគមន៍ជាមួយបរិស្ថានផងដែរ។

លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍរបស់ PPCH B4P បានផ្តល់ទាំងផែនទីចង្អុលផ្លូវ និងស្តង់ដារសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។ ស្របតាមលក្ខខណ្ឌវិនិច្ឆ័យនេះ យើងជឿជាក់ថាយើងអាចកែប្រែរាជធានីភ្នំពេញឲ្យក្លាយជាទីក្រុងចីរភាពគម្រូ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់អ្នកជំនាន់ក្រោយ ក្នុងការអភិវឌ្ឍន៍ដោយគិតគូរជាមួយនឹងធម្មជាតិជុំវិញផងដែរ។

យើងសូមថ្លែងអំណរគុណចំពោះការប្តេជ្ញាចិត្តរបស់ដៃគូសហការចូលរួមទាំងអស់ ក្នុងការបង្កើតអនាគតបៃតងមួយសម្រាប់រាជធានីភ្នំពេញ។

ដោយសេចក្តីរាប់អាន!

**Dipl.-Ing. Rolf Messerschmidt**

CEO of Eble Messerschmidt Partner
Leader of B4P Work Package“Sustainable Neighbourhoods“; DGNB Senior Auditor and Member of the Technical Board

**Dr. -Ing. Stephan Anders**

Director Network and Consulting
German Sustainability Building Council (DGNB)
Member of the B4P Expert Advisory Board




**រូបភាពទី១៖** ទិដ្ឋភាពរួមនៃសមាសភាគគោលរបស់ឧបករណ៍-បរិវត្តកម្ម PPCH-B4P។ ការបោះពុម្ពផ្សាយបច្ចុប្បន្នឆ្លើយតបទៅនឹងជំពូកដំបូងនៃលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍។ ប្រភព៖ Eble Messerschmidt Partner ។

# សេចក្តីផ្តើម

## ការពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងដំណាក់កាលអនុវត្ត B4P ឆ្នាំ២០២៥ - ២០២៧

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ នគរូបនីយកម្មដ៏ឆាប់រហ័សនៃរាជធានីភ្នំពេញបាននាំឲ្យទីក្រុងរីករាលដាល ដោយកង្វះខាតគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរួមទាំងការពង្រីកហេដ្ឋារចនាសម្ព័ន្ធដោយ មិនបានគ្រោងទុក ការរិចរិលធនធានបរិស្ថាន និងការបាត់បង់តុល្យភាពសង្គម។ ដោយមានតម្រូវការលំហទីក្រុង ដែលមានគុណភាពជីវិត និងចីរភាពជាងមុន កត្តានេះបានបង្កឲ្យមានការចាប់អារម្មណ៍ពីសំណាក់វិស័យសាធារណៈ និងវិស័យឯកជនក្នុងការបញ្ចូលលក្ខខណ្ឌវិនិច្ឆ័យ តាមបែបសមាហរណកម្ម ដែលផ្តោតសំខាន់លើបរិស្ថានសង្គម និង គុណភាពសេដ្ឋកិច្ចនៃតំបន់ប្រជុំជនថ្មីដែលភាគច្រើនជាតំបន់លំនៅឋាន។

លក្ខខណ្ឌវិនិច្ឆ័យនេះ នឹងដើរតួនាទីក្នុងការវាយតម្លៃកម្រិតចីរភាព នៃតំបន់រស់នៅពហុមុខងារថ្មី ព្រមទាំងតម្រូវការសំខាន់ៗសម្រាប់អ្នកប្រើប្រាស់ ដែលត្រូវទទួលបានពីការអភិវឌ្ឍន៍នោះ។
ឧបករណ៍វាយតម្លៃនេះធ្វើឡើង ដើម្បីពិចារណាលើកត្តាផ្សេងៗ ដែលជួយដល់គុណភាពការរស់នៅ ភាពធន់ និងចីរភាពនៃសហគមន៍ក្បែមក្សាន្ត ដើម្បីជួយកែលម្អគុណភាពជីវិតរបស់អ្នករស់នៅអ្នកធ្វើការ និងទេសចរណ៍ផងដែរ។ លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍នេះគឺត្រូវបានរៀបចំដោយសមាសភាគក្រុមការងារ “សហគមន៍ប្រកបដោយចីរភាព B4P” សហការជាមួយ គណកម្មការអគារបៃតងនៃប្រទេសអាល្លឺម៉ង់ (DGNB) ។ ការចង់ក្រងនេះក៏បានក្តោបនូវលទ្ធផល និងចំណេះដឹងពីការពិសោធន៍ស្រាវជ្រាវនៃមុខជំនាញផ្សេងៗក្នុង (ដៃគូសហការ B4P) ដោយរួមបញ្ចូលនូវគុណភាព និងស្តង់ដារនៃប្រព័ន្ធវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សា អគារបៃតងអាល្លឺម៉ង់ ដែលតម្រូវបរិបទរាជធានីភ្នំពេញ។ ស្របទៅនឹងក្របខ័ណ្ឌឧបករណ៍បរិវត្តកម្ម PPCH B4P លក្ខខណ្ឌទាំងអស់ត្រូវបានចែកជា ៦ ជំពូក៖

- ការរចនាទីក្រុងបែបសមាហរណកម្ម
- ហេដ្ឋារចនាសម្ព័ន្ធបៃតង ខៀវ
- ការចល័តប្រកបដោយចីរភាព
- ការការពារអាកាសធាតុ និងលំហូរថាមពល
- បរិយាប័ន្នសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន
- អភិបាលកិច្ច និងការចូលរួម



### ការរួមចំណែក

*ពីលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៏ទៅកាន់ សំណុំគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ*

**រូបភាពទី២៖** ទិដ្ឋភាពរួមនៃការចូលរួមពី NEC ទៅកាន់ សំណុំគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ / UN-Sustainable Development Goals
ប្រភព៖ Eble Messerschmidt Partner



# III ការអនុវត្តលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍

លក្ខខណ្ឌវិនិច្ឆ័យរបស់ B4P និងសេចក្ដីណែនាំរបស់ B4P មានទំនាក់ទំនងរវាងគ្នាដោយឧបករណ៍ទាំងពីរនេះជាសមាសធាតុសំខាន់ៗនៃឧបករណ៍បរិវត្តកម្មនៃគម្រោង B4P។

សេចក្ដីណែនាំនេះ ក៏ដើរតួរជាឧបករណ៍មួយដែរ ក្នុងការដាក់បញ្ចូលចំណុចចីរភាពផ្សេងៗចូលទៅក្នុងគម្រោង ដើម្បីបំពេញនូវលក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍។ ក្នុងជំពូកនីមួយៗនៃការវិនិច្ឆ័យក៏មានភ្ជាប់ជាមួយសេចក្ដីណែនាំ B4P ដែលស្របទៅនឹង ប្រធានបទនៃជំពូកនោះផងដែរ។

នៅពេលចាប់ផ្ដើមការអភិវឌ្ឍន៍សហគមន៍ណាមួយគឺ គួរមានការកំណត់ឲ្យបានច្បាស់លាស់នូវគោលដៅគម្រោងរួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ។ ក្នុងបរិបទមួយនេះផងដែរ គឺគួរយកសេចក្ដីណែនាំ B4P មកធ្វើការដាក់បញ្ចូលជាប្រព័ន្ធក្នុងការរៀបចំផែនការ។

អំឡុងពេលរៀបចំផែនការដំណាក់កាលដំបូង គួរតែមានជម្រើសជាច្រើន ដែលផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យ Build4People។ ការវិនិច្ឆ័យជាបឋម ដែលផ្ដោតខ្លាំងទៅលើ លក្ខខណ្ឌវិនិច្ឆ័យដំណាក់កាលដំបូង ធ្វើឡើងដើម្បីជួយក្នុងការសម្រេចចិត្តលើជំហានបន្ទាប់ទៀត។

លក្ខខណ្ឌវិនិច្ឆ័យនេះ គួប្រើគ្រប់ដំណាក់កាលនៃការរៀបចំផែនការមេដោយមានការត្រួតពិនិត្យវិនិច្ឆ័យម្ដងហើយម្ដងទៀត ទៅលើគុណភាពចីរភាពដើម្បីធានាបាននូវការបន្សីគ្នា ដែលស្របទៅនឹងគោលដៅផែនការអភិវឌ្ឍន៍។

នៅក្នុងដំណាក់កាលអនុវត្ត ការត្រួតពិនិត្យវាយតម្លៃជាប្រចាំ គួរដាក់បញ្ចូលក្នុងរបាយការណ៍គម្រោង ដើម្បីសង្កេតមើលគុណភាពចីរភាពនៃការដំណើរការរបស់សហគមន៍ ដែលជាយន្តការក្នុងការធានាគុណភាពគម្រោងផងដែរ។

សម្រាប់ដំណាក់កាលវាយតម្លៃវិញគឺមានតារាងវិនិច្ឆ័យគម្រោងព្រមទាំងសូចនាករ និងទម្រង់នៃការបង្ហាញនូវលទ្ធផលនានាត្រូវបានភ្ជាប់ជាមួយឧបករណ៍វាយតម្លៃគម្រោង ដែលត្រូវបានពិចារណាយ៉ាងល្អិតល្អន់។




**រូបភាពទី៣៖** ទំនាក់ទំនងរវាងលក្ខខណ្ឌវិនិច្ឆ័យ និងការណែនាំរបស់ Build4People។
ប្រភព៖ Eble Messerschmidt Partner ។

## លក្ខខណ្ឌវិនិច្ឆ័យ ចីរភាពដំណាក់កាលដំបូង

*ឥទ្ធិពលធំ និងកម្លាំងតិច ក្នុងដំណាក់កាលដំបូងនៃគម្រោង*

ការសម្រេចចិត្ត ដែលមានមូលដ្ឋានច្បាស់លាស់នៅដំណាក់កាលដំបូងនៃការរៀបចំគម្រោង គឺមានសារៈសំខាន់ក្នុងការទទួលបានគម្រោងមួយដែលមានចីរភាពបានយូរអង្វែង និងសន្សំសំចៃធនធាននាពេលអនាគត។ នៅដំណាក់កាលនេះ ការជ្រើសរើសទីតាំង ការធ្វើផែនការប្រើប្រាស់ដី និងការចែកលំហបៃតងជាគន្លឹះ ដែលអាចមានឥទ្ធិពលដល់ដំណើរការអនុវត្តការងារបរិស្ថាន។ ការកែប្រែ និងអន្តរាគមន៍នៅក្នុងដំណាក់កាលដំបូងនេះដែរ គឺមានប្រសិទ្ធភាពខ្លាំងបើធៀបទៅនឹងដំណាក់កាលសាងសង់ ពេលដំណើរការនិងដំណាក់កាលថែទាំព្រោះទំហំការងារ និងអ្វីដែលអាចផ្លាស់ប្ដូរនៅពេលអនុវត្តគម្រោងគឺតិចជាង និងចំណាយច្រើនផងដែរ។ ដូច្នេះហើយបានជាការពិចារណារពីសមាសធាតុទាំងនោះជាមុន គឺអាចជួយកាត់បន្ថយ ការប៉ះពាល់ធនធានធម្មជាតិ និងសម្រេចបាននូវ ការដំណើរការដោយរលូនពេញមួយវដ្ដជីវិតនៃគម្រោងនោះ។

នគរូបនីយកម្មនៃរាជធានីភ្នំពេញបានផ្ដល់ទាំងឱកាស និងជាឧបសគ្គសម្រាប់ការអភិវឌ្ឍភូមិ-ដ្ឋានសហគមន៍ប្រកបដោយចីរភាព។ សាលាក្រុងនានាតែងជួបផលលំបាកក្នុងការបម្លែងគោលដៅចីរភាពឲ្យទៅជាវិធានការ សម្រាប់ការអនុវត្ត-ដោយហេតុ ខ្វះធនធាននិងឧបករណ៍។ ដូច្នេះហើយលក្ខខណ្ឌវិនិច្ឆ័យប្រកបដោយចីរភាពដំណាក់កាលដំបូងនេះ បានផ្ដល់ជាទម្រង់ក្រប-ខណ្ឌមួយ សម្រាប់អាជ្ញាធរក្នុងការធ្វើផែនការ និងអនុវត្តសហគមន៍មានចីរភាព។ លក្ខខណ្ឌទាំងនេះ នឹងជួយក្នុងការកំណត់តម្រូវការរបស់គម្រោងឲ្យបានច្បាស់លាស់ និងមានតម្លាភាព ហើយកាត់បន្ថយហានិភ័យផ្សេងៗ ក៏ដូចជាការរៀបចំតំបន់ប្រជុំជន ដែលធន់នឹងអាកាសធាតុ ហើយមានលក្ខណៈត្រៀមសម្រាប់នាអនាគត។ លក្ខខណ្ឌវិនិច្ឆ័យនេះក៏ដើរតួរជាឧបករណ៍អនុវត្តមួយក្នុងការសម្របការកសាងផែនការភូមិដ្ឋានទៅនឹងគោលដៅធំរបស់រដ្ឋបាលក្រុងដែរ ដោយជួយអាជ្ញាធរគ្រប់គ្រង ការរីកលូតលាស់របស់ភូមិដ្ឋាន ហើយរក្សាបាននូវគុណភាពបរិស្ថាន និងសុខុមាលភាពរបស់សហគមន៍។

សម្រាប់អ្នកអភិវឌ្ឍន៍អចលនទ្រព្យឯកជនវិញ លក្ខខណ្ឌវិនិច្ឆ័យដំណាក់កាលដំបូងនេះ គឺផ្ដល់ជាមាគ៌ាក្នុងការរចនា និងការគ្រប់គ្រងគម្រោងដោយភ្ជាប់ជាមួយនឹងគុណសម្បត្តិធម្មជាតិ និងអត្ថប្រយោជន៍សង្គម។ ទន្ទឹមនឹងនេះលក្ខខណ្ឌនេះគេអាចប្រើ សម្រាប់ទទួលបានស្តង់ដាអន្តរ-ជាតិដូចជា “វិញ្ញាបនបត្រខណ្ឌរបស់ក្រុមប្រឹក្សាអគារបៃតងអាល្លឺម៉ង់ DGNB " Certification System For Districts "ក្នុងនាមជាសហគ្រាសមានចក្ខុវិស័យ និងគិតពីបរិស្ថាន។ ការដើរស្របនឹងក្របខណ្ឌចីរភាពគឺមិនត្រឹមតែលើកកម្ពស់មុខមាត់នៃគម្រោងប៉ុណោះនោះទេ វាក៏អាចផ្ដល់ភាពទាក់ទាញទៅកាន់អ្នកពាក់ព័ន្ធផ្សេងៗទៀត និងអ្នករស់នៅក្នុងគម្រោងនោះនៅថ្ងៃអនាគត។

លក្ខខណ្ឌវិនិច្ឆ័យទាំងអស់នេះគឺ ធ្វើឡើងដោយផ្អែកលើប្រភពច្រើន ដែលរួមមាន “ វិញ្ញាបនបត្រខណ្ឌរបស់ ក្រុមប្រឹក្សាអគារបៃតងនៃប្រទេសអាល្លឺម៉ង់ DGNB Certification System-For Districts ” កម្រងសៀវភៅ The Ecocity “ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ២០១៨ - ២០៣០ ” និងលទ្ធ-ផលរបស់ B4P-ECTL )”។ ប្រភពទាំងនេះផ្ដល់ជាមាគ៌ាអនុវត្តជាក់ស្តែង សម្រាប់លើកកម្ពស់ដំណើរការចីរភាពផ្សេងៗ នៃគម្រោងភូមិដ្ឋានក្នុងរាជធានីភ្នំពេញ។

## លក្ខខណ្ឌវិនិច្ឆ័យគោលដំណាក់កាលដំបូង

*សម្រាប់ការអភិវឌ្ឍន៍សហគមន៍ ប្រកបដោយចីរភាព*

| | |
|---|---|
| ការផ្សារភ្ជាប់សហគមន៍ និងទីក្រុង | ផ្លូវចូលសហគមន៍រួមមាន ឬមិនមានការគ្រប់គ្រងចរាចរណ៍ចេញចូលត្រូវផ្សារភ្ជាប់ទៅនឹងផ្លូវជុំវិញ។ |
| ដង់ស៊ីតេអគារ | សន្ទស្សន៍ផ្ទៃអគារសរុបជាអប្បបរមា ១.៥ ឬនៅក្នុងកម្រិតមួយ ដែលបានចែងដោយប្រភេទដីអាចសាងសង់បាន ក្នុងប្លង់គោលប្រើប្រាស់ដីបច្ចុប្បន្នភាព។ |
| ការប្រើប្រាស់ដីពហុមុខងារ ដោយមានតុល្យភាព | យ៉ាងហោចបាន ១០% ក្នុងមួយប្លុកៗនៅក្នុងបុរី។ |
| លំហសាធារណៈបៃតង | លំហបៃតងដែលមានជាអប្បបរមា ១០% នៃផ្ទៃដីអភិវឌ្ឍន៍ទាំងអស់។ |
| ហេដ្ឋារចនាសម្ព័ន្ធខៀវ | ការវិភាគទៅលើហានិភ័យទឹកជំនន់ត្រូវបានធ្វើឡើង និងត្រៀមជាគំនិត ដើម្បីជៀសវាងករណីមានទឹកជំនន់នៅលើដីគម្រោង ឬតំបន់ជុំវិញ។ |
| បរិយាកាស សម្រាប់ អ្នកថ្មើរជើង និងជិះកង់ | មានជាទំហំធ្លាសមមាត្រសម្រាប់ ការធ្វើដំណើរល្បឿនយឺត ដោយមានទទឹងជាអប្បបរមា ២ម៉ែត្រ សម្រាប់អ្នកថ្មើរជើង និងសម្រាប់អ្នកជិះកង់វិញជាអប្បបរមា ១.៨មែត្រ ក្នុងមួយគន្លង។ |
| ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ មធ្យោបាយដឹកជញ្ជូន សាធារណៈ | ការធ្វើសមាហរណកម្ម តភ្ជាប់មធ្យោបាយដឹកជញ្ជូន (ដូចជា តុតុ ម៉ូតូឌុប តាក់ស៊ី) ជាមួយប្រព័ន្ធដឹកជញ្ជូនមេដោយមានកន្លែងរងចាំ និងកន្លែងទម្លាក់ ឬយកអ្នកដំណើរ។ |
| អគារដែលសន្សំសំចៃថាមពល | យុទ្ធសាស្ត្រ រចនាអកម្ម ដោយប្រើខ្យល់ និងពន្លឺធម្មជាតិត្រូវបានយកមកអនុវត្ត ដើម្បីកាត់បន្ថយតម្រូវការម៉ាស៊ីនត្រជាក់ ឬឧបករណ៍ប្រើអគ្គីសនីសម្រាប់បន្ថយកម្ដៅផ្សេងៗទៀត។ |
| ការរចនាផ្ដោតលើវដ្ដជីវិតនៃអគារ | កាត់បន្ថយ ២០% នៃបេតុង ដែក និងខ្សាច់ បើធៀបទៅនឹងអគារដែលមានមុខងារ និងទំហំស្រដៀងគ្នា ហើយបានធ្វើការគណនា និងមានភស្តុតាង។ |
| សហគមន៍វិលជុំ | បានកំណត់វិធានការគ្រប់គ្រងកាកសំណល់សម្រាប់ការសាងសង់គម្រោងអភិវឌ្ឍន៍។ |
| លំនៅឋានតម្លៃសមរម្យ | ១០% នៃលំនៅឋាន បានគ្រោងសម្រាប់លំនៅឋានតម្លៃសមរម្យ |
| ភាពចម្រុះនៃសង្គម | អគារពហុមុខងារ និងជម្រើសគេហដ្ឋានសម្រាប់អ្នករស់នៅ ឬគ្រួសារដែលមានចំណូលផ្សេងៗគ្នាត្រូវបានគិតគូររួចជាស្រេច។ |
| ការរាប់បញ្ចូល និងចូលរួមពីសហគមន៍ | កម្មវិធីផ្សព្វផ្សាយព័ត៌មានពីគម្រោងត្រូវបានធ្វើឡើងក្នុងដំណាក់កាលរៀបចំគម្រោង និងសាងសង់។ |
| របៀបរស់នៅដោយចីរភាព | បានបង្កើតការផ្សព្វផ្សាយសម្រាប់លើកស្ទួយការរស់នៅបែបចីរភាព។ |

# IV លក្ខខណ្ឌវិនិច្ឆ័យតំបន់ត្រូវអភិវឌ្ឍន៍
## B4P TTB GL




**រូបភាពទី៦៖** ក្នុងអំឡុងពេលនៃមន្ទីរពិសោធន៍ផ្លាស់ប្តូរទីក្រុងអេកូឡូស៊ី B4P ឆ្នាំ២០២៣ សហការជាមួយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ Peng Huoth នៅរាជធានីភ្នំពេញ ក្រាហ្វ ដែលគិតគូរយ៉ាងល្អិតល្អន់នេះត្រូវបានបង្កើតឡើង ដើម្បីបង្ហាញពីតម្រូវការក្នុងការរួមបញ្ចូលវិធីសាស្ត្រតាមប្រធានបទនានាពីកញ្ចប់ការងារ B4P ដើម្បីសម្រេចបាននូវការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព។

- ការផ្លាស់ប្តូរឥរិយាបថ
- អគារប្រកបដោយនិរន្តភាព
- សហគមន៍ប្រកបដោយនិរន្តភាព
- ទីក្រុងបៃតង
- អាកាសធាតុទីក្រុង
- បរិវត្តកម្មទីក្រុងប្រកបដោយនិរន្តភាព





លក្ខណៈវិនិច្ឆ័យ ០១.០




# ការរចនាទីក្រុងបែបសមាហរណកម្ម

គោលដៅនៃលក្ខខណ្ឌវិនិច្ឆ័យសមាហរណកម្មការរៀបចំគម្រោងអភិវឌ្ឍន៍នេះ គឺដើម្បីធានាការធ្វើសមាហរណកម្មដោយរលូនចំពោះការរៀបចំតំបន់ថ្មីក្នុងទីក្រុង ជាមួយនឹងប្រជាជនក្នុងតំបន់នោះផងដែរ ថែមទាំងផ្តល់នូវសហគមន៍ ដែលពួកគាត់អាចបំពេញតម្រូវការប្រចាំថ្ងៃបាន ដែលមានសេវាកម្មដូចជា សាលារៀន មន្ទីរពេទ្យ និងកន្លែងកម្សាន្តហើយស្ថិតនៅត្រឹមចម្ងាយមួយ ដែលជិតសម្រាប់ពួកគាត់។ លក្ខខណ្ឌនេះ មានគោលបំណងបង្កើតឲ្យមាននូវសហគមន៍ ដែលប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដើរតួរក្នុងការថែទាំទាំងសហគមន៍ផង ទាំងតំបន់ជុំវិញផង។

## ចំណុចទាក់ទង

១. **ចីរភាព៖** ដោះស្រាយបញ្ហាបរិស្ថាន និងសង្គមហើយលើកកំពស់ការអនុវត្តផ្សេងៗដែលគោរពបរិស្ថាន។

២. **ប្រសិទ្ធភាព៖** ធ្វើការចាត់ចែងធនធាន និងកាត់បន្ថយកាកសំណល់ប្រកបដោយប្រសិទ្ធភាពជាងមុន និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

៣. **សុខុមាលភាពរបស់សហគមន៍៖** បង្កើតលំហដែលអោយមនុស្សរស់នៅមានទំនាក់ទំនងល្អ និងបំពេញនូវតម្រូវការផ្សេងៗរបស់មនុស្ស ក៏ដូចជាលើកកម្ពស់គុណភាពជីវិតរបស់អ្នករស់ក្នុងសហគមន៍ផងដែរ។

**រូបភាពទី៧៖** រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.



M *អប្បបរមា*

T *គោលដៅ*

## ការផ្សារភ្ជាប់សហគមន៍ និងទីក្រុង |

ការផ្សារភ្ជាប់គ្នានេះគឺ សំដៅទៅលើការធ្វើដំណើរក្នុងទីក្រុង ដែលមានល្បឿនលឿន និងងាយស្រួល ដោយផ្តល់តម្លៃលើ បណ្តាញដឹកជញ្ជូនដែលគិតទុកបានល្អ ផ្លូវសម្រាប់អ្នកថ្មើរជើង និងលំហសាធារណៈដែលមានបរិយាប័ន្ន ហើយទាំងអស់នេះគឺនាំឲ្យមានបរិយាប័ន្នសង្គម ការធ្វើសមាហរណកម្ម និងការចល័តដោយរលូន។

- M **ផ្លូវចូលសហគមន៍ (ទាំងមាន ឬមិនមានការគ្រប់គ្រងចរាចរណ៍ចេញចូល) ត្រូវផ្សារភ្ជាប់ទៅនឹងផ្លូវជុំវិញ**
- ភូមិដ្ឋានត្រូវបានបែងចែកជាមុខងារ និងបានពិចារណា បញ្ហាអន្តរកាល រវាងមុខងារទាំងនោះ។
- មិនមានការរឹតត្បិតការចេញចូលសម្រាប់អ្នកដែលមិនរស់នៅក្នុងសហគមន៍នោះ
- T ភូមិដ្ឋានសហគមន៍ដែលគ្រោងទុកដោយមិនរឹតត្បិតការចេញចូល

## ដង់ស៊ីតេអគារ |

ដង់ស៊ីតេអគារគឺ សំដៅលើការប្រមូលផ្តុំអគារនៅក្នុងបរិវេនតំបន់ ដែលបានកំណត់ ឬក៏ងាយស្រួលយល់គឺ ចំនួនអគារក្នុងកត្តាទំហំដីមួយ។ ដង់ស៊ីតេអគារនេះគឺ មានឥទ្ធិពលច្រើនទៅលើការអភិវឌ្ឍន៍ទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ហើយនិងការប៉ះពាល់ធនធានធម្មជាតិ និងសង្គម។
** សន្ទស្សន៍ផ្ទៃក្រឡាអគារ (FAR)*
** ផលធៀបផ្ទៃក្រឡាបាតសំណង់នឹងផ្ទៃដីឡូត៍ (BCR)*

- M **សន្ទស្សន៍ប្រើប្រាស់ដីជាអប្បបរមា ១.៥ ឬនៅក្នុងកម្រិតមួយដែលបានចែងដោយ ប្រភេទដីអាចសាងសង់បាន ក្នុងប្លង់គោលប្រើប្រាស់ដីបច្ចុប្បន្នភាព។**
- សន្ទស្សន៍ប្រើប្រាស់ដី ២.០ ឬខ្ពស់ជាងនេះ ហើយផលធៀបផ្ទៃក្រឡាបាតសំណង់នឹងផ្ទៃដីឡូត៍ មិនឲ្យលើសពី៨០%
- សន្ទស្សន៍ប្រើប្រាស់ដី ២.៥ ឬខ្ពស់ជាងនេះ ហើយផលធៀបផ្ទៃក្រឡាបាតសំណង់នឹងផ្ទៃដីឡូត៍ មិនឲ្យលើសពី៨០%
- T សន្ទស្សន៍ប្រើប្រាស់ដី ៣.០ ឬខ្ពស់ជាងនេះ ហើយផលធៀបផ្ទៃក្រឡាបាតសំណង់នឹងផ្ទៃដីឡូត៍ មិនឲ្យលើសពី៨០%

## ការប្រើប្រាស់ដីពហុមុខងារដោយមានតុល្យភាព |

ការប្រើប្រាស់ដីពហុមុខងារដោយមានតុល្យភាពនេះគឺ សំដៅទៅលើការដាក់មុខងារចម្រុះចូលទៅតំបន់ក្នុងទីក្រុងមួយ ដែលរួមមានដូចជា លំនៅឋាន អាជីវកម្ម និងកន្លែងកម្សាន្តដោយចង់ឲ្យបង្កើតបានជាសហគមន៍ចីរភាពមួយដែលរស់រវើក មានមុខងារចម្រុះហើយលើកតម្កើងការចល័តដោយមិនប្រើយានយន្ត។

- M **គ្រប់តំបន់មុខងារដែលដំណើរការទាំងអស់មានបញ្ចូលមុខងារបន្ថែមយ៉ាងតិច ២ ទៀតដោយមួយមុខងារគ្របដណ្តប់ជាអប្បបរមា ១០% នៃផ្ទៃដីឡូត៍សរុប**
- គ្រប់តំបន់មុខងារដែលដំណើរការទាំងអស់មានបញ្ចូលមុខងារបន្ថែមយ៉ាងតិច ៣ ទៀតដោយមួយមុខងារគ្របដណ្តប់ជាអប្បបរមា ១០% នៃផ្ទៃដីឡូត៍សរុប
- T សហគមន៍បានបញ្ចូលមុខងារបន្ថែមពី ៤០% ទៅ៨០% នៃផ្ទៃដីឡូត៍សរុប និងរៀបចំនៅក្នុងរយៈចម្ងាយសេវាកម្ម ៧៥០ម៉ែត្រ ទៅ១០០០ម៉ែត្រ

## តម្រូវការប្រចាំថ្ងៃ និងហេដ្ឋារចនាសម្ព័ន្ធសង្គម |

ហេដ្ឋារចនាសម្ព័ន្ធសង្គមសំដៅទៅលើកន្លែង និងបរិក្ខារផ្សេងៗដែលជួយទ្រទ្រង់សុខុមាលភាពសង្គមដូចជា សាលារៀន មណ្ឌលសុខភាព មជ្ឈមណ្ឌលសហគមន៍ និងលំហសាធារណៈ ដែលទាំងអស់នេះជួយទៅគុណភាពជីវិតជារួមនៅក្នុងសហគមន៍។

- M **មានការគ្រោងទុក មជ្ឈមណ្ឌល ឬទីប្រជុំសហគមន៍ ដែលអាចចូលទៅប្រើបានដោយ អ្នករស់នៅក្នុងសហគមន៍នោះផង និងអ្នកក្រៅសហគមន៍ផង។**
- មានការគ្រោងទុក មជ្ឈមណ្ឌលអប់រំក៏ដូចជា ឧទ្យាន សួនច្បារសហគមន៍ ឬកន្លែងក្មេងលេង ដែលគិតក្នុងរយៈចម្ងាយសេវាកម្ម ៧៥០ម៉ែត្រ ទៅ១០០០ម៉ែត្រ។
- មានការគ្រោងទុកនូវ ជម្រើសក្នុងការផ្គត់ផ្គង់ទំនិញប្រចាំថ្ងៃដែលគិតក្នុងរយៈចម្ងាយសេវាកម្ម ៧៥០ម៉ែត្រ ទៅ១០០០ម៉ែត្រ។
- T មានការគ្រោងទុកនូវ មជ្ឈមណ្ឌល នៃហេដ្ឋារចនាសម្ព័ន្ធសង្គមទាំង ៥ ប្រភេទដោយក្នុងនោះរួមមាន ការអប់រំ វប្បធម្ម សុខាភិបាល ផ្សារ ឬកន្លែងផ្គត់ផ្គង់ទំនិញប្រចាំថ្ងៃ ហើយរួមទាំង ការកម្សាន្ត និងកីឡាដោយគិតទុកក្នុងរយៈចម្ងាយសេវាកម្មណាមួយដែលសមរម្យ។

## លំហសាធារណៈដែលរស់រវើក |

លំហសាធារណៈដែលរស់រវើកគឺជា ទីកន្លែងដែលមានជីវិត មានភាពសកម្ម និងទាក់ទាញមនុស្សហើយលើកទឹកចិត្តឲ្យមានអន្តរកម្មសង្គម កម្មវិធីវប្បធម៌ និងសកម្មភាពកម្សាន្តផ្សេងៗ ដែលទាំងអស់នេះគឺជំរុញឲ្យមានជាស្មារតីរួមមួយសម្រាប់ប្រជាជន។

- M **បានទុកជាអប្បបរមា ១៥% នៃផ្ទៃដីសរុប សម្រាប់ធ្វើជាលំហសាធារណៈ**
- គ្រប់លំហសាធារណៈទាំងអស់គឺអាចចូលប្រើបានជាសាធារណៈ និងគ្មានរបាំង
- បានអនុវត្តវិធានការការពារសុវត្ថិភាពសម្រាប់មនុស្ស និងចរាចរណ៍
- ការរចនាបានដាក់បញ្ចូលកន្លែងអង្គុយគ្រប់គ្រាន់ និងមានផាសុកភាព ដែលជាសម្បត្តិសាធារណៈ និងមិនមែនជារបស់អាជីវកម្មឯកជនណាមួយ។
- ការរចនាមានការបត់បែនបាន និងអាចដាក់សម្មភាពផ្សេងៗបានតាមកាលៈទេសៈ (ឧទាហរណ៍៖ ផ្សារបណ្តោះអាសន្ន សម្រាប់កម្មវិធីផ្សេងៗ ឬជាទីកន្លែងកម្សាន្ត)
- ការរៀបចំគម្រោងបានដាក់បញ្ចូល ផ្ទៃគ្របដណ្តប់ដោយដើមឈើ និងរុក្ខជាតិ ច្រើនជាង ៣០% នៃផ្ទៃសរុប។
- T លំហសាធារណៈផ្សេងៗបានរាប់បញ្ចូលលក្ខខណ្ឌវិនិច្ឆ័យគុណភាពទាំង ១២ សម្រាប់ការការពារអាកាសធាតុ ផាសុខភាព និងភាពសប្បាយរីករាយ។

***លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖**

- ការរចនាត្រូវទទួលបានការយល់ស្របពី ក្រុមប្រឹក្សាភិបាលដោយពិចារណាទៅលើកេរដំណែលវប្បធម៌។

សម្រាប់ព័ត៌មានបន្ថែម៖
ឧបករណ៍បរិវត្តកម្ម B4P
០២.១
សេចក្តីណែនាំអំពី
ការរចនាទីក្រុង
បែបសមាហរណកម្ម



# ហេដ្ឋារចនាសម្ព័ន្ធ បៃតង ខៀវ

គោលបំណងនៃលក្ខខណ្ឌវិនិច្ឆ័យហេដ្ឋារចនាសម្ព័ន្ធបៃតង ខៀវ នោះគឺ ដើម្បីធានាការប្រើប្រាស់លំហបៃតងឲ្យមានតុល្យភាព ទន្ទឹមនឹងនោះ ដើម្បីធ្វើសមាហរណកម្មផែនការគ្រប់គ្រងទឹក និងយុទ្ធសាស្ត្រសម្របនឹងអាកាសធាតុបញ្ចូលទៅក្នុងគម្រោង។
ចំណុចនេះផ្តោតធំលើភាពធន់នៃសហគមន៍តាមរយៈលក្ខណៈសម្បត្តិមួយចំនួន រួមមានដំបូលបៃតង ស្តុនស្តុកទឹកភ្លៀង និងប្រព័ន្ធលូបង្ហូរទឹកដែលចីរភាព ដោយលក្ខណៈសម្បត្តិទាំងអស់នេះ ជួយក្នុងការកាត់បន្ថយប៉ារ៉ាបូលកម្តៅ កាត់បន្ថយបញ្ហាតម្រូវការនៃទឹក និងជួយផ្តល់លំនឹង ដល់បរិយាកាសជុំវិញអគារ និងសុខុមាលភាពអាកាសធាតុ។

**រូបភាពទី៨៖** រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.

## ចំណុចទាក់ទង

១. **ការគ្រប់គ្រងទឹកជំនន់៖** កាត់បន្ថយហានិភ័យទឹកជំនន់តាមរយៈប្រព័ន្ធលូបង្ហូរទឹក ដែលមានចីរភាព។

២. **ការលើកកម្ពស់ជីវៈចម្រុះ៖** បង្កើតជម្រកសត្វតូចៗ និងលើកកម្ពស់ ភាពចម្រុះនៃអេកូឡូស៊ី។

៣. **ភាពធន់នឹងអាកាសធាតុ៖** ជួយភាពធន់របស់ទីក្រុងឲ្យប្រសើរជាងមុន ដោយឆ្លើយតបទៅនឹងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ តាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងទឹកដែលមានចីរភាព។

៤. **តម្រូវការទឹក៖** ធ្វើសមាហរណកម្មប្រព័ន្ធអេកូឡូស៊ីដើម្បីកែលំអប្រភពទឹកប្រើប្រាស់ កែច្នៃទឹកយកមកប្រើឡើងវិញ ដើម្បីកាត់បន្ថយតម្រូវការផ្គត់ផ្គង់ទឹករបស់រដ្ឋ។





M អប្បបរមា
T គោលដៅ

### លំហបៃតងសាធារណៈ |

លំហបៃតងសាធារណៈគឺ សំដៅទៅលើទីធ្លាសហគមន៍ដែលនៅខាងក្រៅអគារដូចជាឧទ្យាន ឬសួនច្បារដែលរៀបចំឡើង ដើម្បីប្រើប្រាស់ដោយសាធារណជន។ លំហទាំងនេះ ជួយជំរុញឲ្យមានអន្តរកម្មរវាងគ្នាក្នុងសហគមន៍ ផ្តល់ជាសកម្មភាពកម្សាន្តផ្សេងៗ ជួយឲ្យមានសុខភាពល្អ និងជួយបន្ធូរអារម្មណ៍អ្នករស់នៅក្នុងសហគមន៍ ដែលទន្ទឹមនឹងនោះគឺជួយដល់អាកាសធាតុមីក្រូក្នុងទីក្រុង និងផាសុខភាពអាកាសធាតុ។

- M លំហបៃតងសាធារណៈគ្របដណ្តប់ ១០% នៃផ្ទៃដីសរុប និងគ្របដណ្តប់ជាអប្បបរមា ១០០ម៉ែត្រការ៉េ នៃផ្ទៃដី។
- លំហបៃតងសាធារណៈបានគ្រោងទុកមុន និងបានគិតទុកនៅក្នុងរយៈចម្ងាយសេវាកម្ម ៧៥០ម៉ែត្រ ទៅ ១០០០ម៉ែត្រ (ប្រហាក់ប្រហែលទៅនឹងរយៈពេលដើរ ១៥នាទី)
- ផ្ទៃគ្របដណ្តប់ដោយរុក្ខជាតិទាបៗ និងដើមឈើទុកបានជាអប្បបរមា ២៥% នៃលំហបៃតង
- រុក្ខជាតិ ស្មៅ និងផ្ទៃជម្រាបទឹកគ្របដណ្តប់បាន ៣០% នៃផ្ទៃដីសរុប
- T លំហបៃតងសាធារណៈបានគ្រោងទុកជាបណ្តាញតភ្ជាប់គ្នាតាមរយៈ ដីពាក់កណ្តាលសាធារណៈ ឬលំហបៃតងឯកជន ដែលមានចម្ងាយជាអតិបរមា ១០០០ម៉ែត្រ។

### ហេដ្ឋារចនាសម្ព័ន្ធបៃតង |

បណ្តាញដែលបានរៀបចំជាយុទ្ធសាស្ត្រ និងតំបន់ពាក់កណ្តាលធម្មជាតិនានា ដោយរួមបញ្ចូលសមាសភាគបរិស្ថានត្រូវបានរៀបចំ និងគ្រប់គ្រងដើម្បីផ្តល់នូវ សេវាកម្មប្រព័ន្ធអេកូឡូស៊ីទូលំទូលាយ ព្រមទាំងការលើកកម្ពស់ជីវសាស្ត្រចម្រុះ។

- M បានធ្វើការវិភាគស្ថានភាពអេកូឡូស៊ីនៃលំហបៃតង និងប្រភេទពូជរុក្ខជាតិ
- ផ្ទៃដណ្តប់ Biotope គឺស្មើរនឹង ០.៥ ≤ BAF ≤ 0.9
- ផ្ទៃបៃតងបើកចំហរធំៗ (៥០០ម៉ែត្រការ៉េ) ដែលជាប់ទៅនឹងខណ្ឌ គឺបានភ្ជាប់តាមរយៈ (ហេដ្ឋារចនាសម្ព័ន្ធបៃតង) របស់ខណ្ឌ
- T ផ្ទៃបើកចំហអេកូឡូស៊ី ដែលពាក់ព័ន្ធគ្នានៅក្នុងខណ្ឌដែលធំជាង ១០០០ម៉ែត្រការ៉េ គឺត្រូវប្រើប្រាស់រួម

### ហេដ្ឋារចនាសម្ព័ន្ធខៀវ |

ហេដ្ឋារចនាសម្ព័ន្ធខៀវជាប្រព័ន្ធអេកូឡូស៊ីទឹកទាំងធម្មជាតិ និងសិប្បនិម្មិតដែលដើរតួរជាហេដ្ឋារចនាសម្ព័ន្ធមានជីវិត។ សមាសធាតុទាំងនោះរួមមានប្រឡាយបៃតង ស្តុនស្តុកទឹកភ្លៀង និងដីលិចទឹកដែលសង់ឡើងដោយមនុស្សដើម្បីគ្រប់គ្រងឥទ្ធិពលនៃអាកាសធាតុសើម។

- M **ការវិភាគទៅលើហានិភ័យទឹកជំនន់ត្រូវបានធ្វើឡើង និងត្រៀមជាគំនិតដើមទង រួចជាស្រេចក្នុងការជៀសវាង ករណីមានទឹកជំនន់នៅលើដីគម្រោង ឬតំបន់ជុំវិញ។**
- មានយុទ្ធសាស្ត្រគ្រប់គ្រងទឹកភ្លៀង ២ ផ្សេងៗគ្នាដែលបានអនុវត្តនៅក្នុង ខណ្ឌ
- មានយ៉ាងតិចយុទ្ធសាស្ត្រគ្រប់គ្រងទឹកភ្លៀង ៣ ផ្សេងៗគ្នាដែលបានអនុវត្តនៅក្នុង ខណ្ឌ
- T បានធ្វើសមាហរណកម្ម ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកភ្លៀង ចូលទៅក្នុងគំនិតរៀបចំទីធ្លាចំហ

### ការអភិវឌ្ឍទីក្រុង ដែលឆ្លើយតបនឹងអាកាសធាតុ |

ការអភិវឌ្ឍន៍ទីក្រុងដែលឆ្លើយតបនឹងអាកាសធាតុ គឺការសម្របនគររូបនីយកម្មទីក្រុងឲ្យដោះស្រាយ និងឆ្លើយតបទៅនឹងឥទ្ធិពលបម្រែបម្រួលអាកាសធាតុ។ ការអភិវឌ្ឍន៍បែបនេះ គឺប្រើយុទ្ធសាស្ត្រដូចជា ការដាក់ហេដ្ឋារចនាសម្ព័ន្ធបៃតង និងបង្កើតភូមិដ្ឋានសហគមន៍ដែលធន់ទៅនឹងអាកាសធាតុដើម្បីកាត់បន្ថយ និងឆ្លើយតបទៅនឹងគ្រោះធម្មជាតិ ក៏ដូចជាស្ថានភាពបម្រែបម្រួលអាកាសធាតុផងដែរ។

- M **បានធ្វើការវិភាគអាកាសធាតុទីក្រុងរួចរាល់**
- បានអនុវត្តអនុសាសន៍អាកាសធាតុទីក្រុងដោយបង្កើនចរន្តខ្យល់ និងកាត់បន្ថយកាំរស្មីព្រះអាទិត្យ ឬកម្តៅលើផ្ទៃដី។
- បានអនុវត្តអនុសាសន៍ស្តីពីអាកាសធាតុទីក្រុងតាមរយៈការបង្កើនភាពត្រជាក់ដោយចំហាយទឹក កាត់បន្ថយការកើនកម្តៅ និងផ្តល់ជាជម្រកភ្លៀង។
- T គ្រប់អនុសាសន៍អាកាសធាតុទីក្រុងទាំងអស់ត្រូវបានបញ្ចូលទៅក្នុងការកសាងផែនការ

**សម្រាប់ព័ត៌មានបន្ថែម៖**
ឧបករណ៍បរិវត្តកម្ម B4P

០២.២
សេចក្តីណែនាំអំពី
ហេដ្ឋារចនាសម្ព័ន្ធ
បៃតង ខៀវ

### *លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖

- បានកំណត់ថវិការសម្រាប់ទឹកស្រោចដំណាំ និងការថែទាំលំហបៃតង
- បានផ្គត់ផ្គង់ទឹកស្អាតសម្រាប់បរិភោគ
- បានអនុវត្តវិធានការពិនិត្យទឹក និងចងជារបាយការណ៍
- បានធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធបៃតងចូលទៅក្នុងកម្រិតអគារ៖ សួនច្បាបៃតង តំបូលបៃតង ផ្ទៃខាងមុខ ឬផ្ទៃមុខអគារបៃតង
- បានគ្រោងទុកនូវការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបៃតង



# ការចល័ត ប្រកបដោយចីរភាព

រូបភាពទី៩៖ រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.

គោលបំណងនៃលក្ខខណ្ឌវិនិច្ឆ័យការចល័ត-ដោយចីរភាពគឺ ដើម្បីលើកស្ទួយមធ្យោបាយ-ដឹកជញ្ជូននៅសហគមន៍ថ្មីក្នុងរាជធានីភ្នំពេញ ដែលមិនប៉ះពាល់បរិស្ថាន ប្រើប្រាស់រយៈពេលខ្លី និងងាយស្រួលប្រើប្រាស់។ ចំណុចនេះផ្តល់អាទិភាពលើមធ្យោបាយដឹកជញ្ជូនសាធារណៈ ការជិះកង់ ថ្មើរជើង និងការចាត់ទុក "ចល័តភាពជាសេវាកម្ម" (MaaS) ដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាន ជួយបង្កើនផាសុខភាពអ្នកធ្វើ-ដំណើរ និងផ្តល់ជម្រើសមធ្យោបាយជាប្រព័ន្ធ ដែលមិនពឹងផ្អែកទាំងស្រុងទៅលើមធ្យោបាយឯកជន។

## ចំណុចទាក់ទង

១. **ការអភិរក្សបរិស្ថានធម្មជាតិ៖** កាត់បន្ថយការបំ-ភាយឧស្ម័នកាបូន ការបំពុលខ្យល់ និងការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីល។

២. **ការលើកតម្កើងសុខភាពផ្លូវកាយ និងផ្លូវចិត្ត៖** លើកទឹកចិត្តឲ្យធ្វើការចល័តដោយសកម្ម (ការដើរថ្មើរជើង ការជិះកង់) ដើម្បីជួយពង្រឹងកាយសម្បទា និងសុខភាព។

៣. **ការសន្សំសំចៃថវិការ ឬសេដ្ឋកិច្ច៖** លើកកម្ពស់-ការអភិវឌ្ឍន៍ទីក្រុងឲ្យមានដង់ស៊ីតេខ្ពស់ ដើម្បីកាត់បន្ថយចំណាយលើការអភិវឌ្ឍន៍ (ការអភិវឌ្ឍន៍ទីក្រុងឲ្យមានដង់ស៊ីតេខ្ពស់ ចូលរួមកាត់បន្ថយការងារ-សាធារណៈការ)។

៤. **សុខុមាលភាពសហគមន៍៖** ការចល័តសកម្មគឺជួយលើកកម្ពស់សុខដុមនីយកម្មសង្គម ដែលជាហេតុនាំឲ្យសហគមន៍មានចំណងល្អ និងរឹងមាំជាងមុន។

Ⓜ អប្បបរមា
Ⓣ គោលដៅ

### ទីកន្លែងដែលរៀបចំឡើងសម្រាប់អ្នកថ្មើរជើង និងជិះកង់ |

ទីកន្លែងដែលរៀបចំសម្រាប់អ្នកថ្មើរជើង និងជិះកង់គឺផ្តល់អាទិភាពធំទៅលើការដើរ និងជិះកង់។ ទាំងនោះរួមមានសមាសធាតុដូចជា ផ្លូវថ្មើរជើងដែលគិតទុកបានល្អ ផ្លូវជិះកង់ និងមានជាវិធានការរូបវន្តផ្សេងៗ ក្នុងការបន្ថយល្បឿនចរាចរណ៍ ដែលជម្រុញឲ្យមានជាការចល័តក្នុងទីក្រុងមួយប្រកបដោយចីរភាព ផ្តល់សុខភាពល្អ និងងាយស្រួលប្រើប្រាស់។

- Ⓜ **បានរៀបចំជាទំហំធ្លាសមមាត្រសម្រាប់ ការធ្វើដំណើរល្បឿនយឺត ដោយមានទទឹងជាអប្បបរមា ២ម៉ែត្រសម្រាប់អ្នកដើរ និងសម្រាប់អ្នកជិះកង់ជាអប្បបរមា ១.៨ម៉ែត្រ ក្នុងមួយគន្លង។**
- ○ ទម្រង់ប្លុកទីក្រុងបានរៀបក្នុងប្រវែងចន្លោះ ១០០ម ទៅ ២០០ម ដើម្បីឲ្យងាយស្រួលដើរ និងជិះកង់។
- ○ បានគ្រោងទុកនូវ បណ្តាញផ្លូវថ្មើរជើង និងជិះកង់ ដោយបានផ្តល់កន្លែងឆ្លងដែលសុវត្ថិភាព និងគ្មានរបាំង ហើយធានា បរិយាប័ន្នអ្នកប្រើប្រាស់ ឬស្រួលប្រើប្រាស់សម្រាប់មនុស្សទូទៅ។
- ○ បានដាក់វិធានការរូបវន្តពន្យឺតល្បឿនចរាចរណ៍ផ្សេងៗចូលទៅក្នុងស្តង់ដាររការរចនាផ្លូវ៖ ឧទាហរណ៍ ផ្លូវកោងទួលបន្ថយល្បឿន បង្រួមគន្លងចរាចរណ៍ ផ្លូវពហុមធ្យោបាយ។
- ○ ផ្លូវថ្មើរជើង និងជិះកង់បានធ្វើឡើងជាលំហដែលមានភាពទាក់ទាញ និងមានផាសុខភាពសម្រាប់អ្នកប្រើប្រាស់ ដោយមានផ្តល់ជាម្លប់ និងជម្រក ទេសភាពបៃតង ដែលមិនត្រូវការថែទាំច្រើន និងប្រើប្រាស់គ្រឿងសង្ហារឹមសាធារណៈណា ដែលប្រើបានយូរ។
- ○ បណ្តាញផ្លូវបានភ្ជាប់ទៅនឹងស្ថាននីយធ្វើដំណើររបស់សហគមន៍។
- Ⓣ អគារមានរួមបញ្ចូល កន្លែងចេញចូលកង់ ចំណតកង់ និងមានជាបរិក្ខារផ្សេងៗទៀតសម្រាប់អ្នកជិះកង់ដូចជា ទូរដាក់ឥវ៉ាន់ កន្លែងងូតទឹក និងកន្លែងផ្លាស់ខោអាវ។

### ហេដ្ឋារចនាសម្ព័ន្ធសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ |

ហេដ្ឋារចនាសម្ព័ន្ធសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈមានរាប់បញ្ចូលសមាសធាតុរូបវន្តផ្សេងៗ ដែលជួយទ្រទ្រង់ប្រព័ន្ធដឹកជញ្ជូនមនុស្សបានចំណុះច្រើន (MRT, BRT) រួមមានទាំងកន្លែងរងចាំរថយន្តក្រុង និងរថ-ភ្លើង ផ្លូវដែក ស្ថានីយ និងមជ្ឈមណ្ឌលផ្សេងៗទៀត។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ គឺជួយលើកស្ទួយមធ្យោបាយធ្វើដំណើរឲ្យ ប្រើរយៈពេលខ្លី និងងាយស្រួលប្រើប្រាស់សម្រាប់សាធារណៈ។

- Ⓜ **ការធ្វើសមាហរណកម្ម មធ្យោបាយដឹកជញ្ជូនតំណរ បញ្ចូលទៅក្នុងផ្លូវ ដោយមានកន្លែងរងចាំ និងកន្លែងទម្លាក់ ឬយកភ្ញៀវ។**
- ○ ការធ្វើសមាហរណកម្ម ពហុមធ្យោបាយដឹកជញ្ជូន ឲ្យនៅក្នុងរយៈចម្ងាយដើរត្រឹមតែ ១០ ទៅ ១៥នាទី ពីគ្នា ដែលរួមបញ្ចូលឡានក្រុង មធ្យោបាយដឹកជញ្ជូនតំណរ និងយានយន្តសហកម្មសិទ្ធិ។
- ○ កន្លែងចាំរថយន្តក្រុងបានគ្រោងទុកជាមុនទាំងជុំវិញ និងក្នុងសហគមន៍ ដោយស្ថិតក្នុងរយៈចម្ងាយដើរពី ១០ ទៅ ១៥នាទី។
- ○ បានផ្តល់ជាស្ថានីយ ពហុមធ្យោបាយដឹកជញ្ជូន។ នៅស្ថានីយរថយន្តក្រុងធំៗ គឺបានផ្តល់ជាកន្លែងចតសុវត្ថិភាពសម្រាប់ម៉ូតូ (ស្ថានីយចុងក្រោយ)។
- Ⓣ គម្រោងចល័តភាពនៃភូមិដ្ឋានសហគមន៍ បានគិតទុកមុននូវការផ្តល់ជាជម្រើសនៃប្រភេទមធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលស្របទៅនឹងប្លង់មេ ចល័តភាពរបស់ ក្រុង ស្រុក និងខណ្ឌ។

### ហេដ្ឋារចនាសម្ព័ន្ធសម្រាប់យានយន្តប្រើប្រាស់ឥន្ធនៈចីរភាព |

ហេដ្ឋារចនាសម្ព័ន្ធសម្រាប់យានយន្តប្រើប្រាស់ឥន្ធនៈចីរភាពរួមមាន កន្លែងសាកឡានអគ្គិសនី កន្លែងបញ្ចូលអ៊ីដ្រូសែន និងមជ្ឈមណ្ឌលផ្សេងៗទៀតដែលជួយផ្គត់ផ្គង់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលមិនប៉ះពាល់បរិស្ថាន ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើឥន្ធនៈហ្វូស៊ីល។

- Ⓜ **បានផ្តល់ជាកន្លែងចតអាទិភាពសម្រាប់យានយន្តអគ្គិសនី**
- ○ បានគ្រោងទុកកន្លែងសាកយានយន្តអគ្គិសនីគ្រប់គ្រាន់សម្រាប់ ១០% នៃកន្លែងចត
- Ⓣ យុទ្ធសាស្ត្រ ឬគម្រោងចល័តភាពក្នុងភូមិដ្ឋានសហគមន៍បានគិតបញ្ចូល យានយន្តប្រើប្រាស់ឥន្ធនៈចីរភាព

***លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖**

- ○ មានវិធានការគ្រប់គ្រងសម្លេង
- ○ បានបញ្ចូល សេវាកម្មហៅមធ្យោបាយដឹកជញ្ជូន (ឧទាហរណ៍៖ Grab Passapp TADA)

### សហគមន៍ ដែលកាត់បន្ថយយានយន្ត |

ភូមិដ្ឋានសហគមន៍ ដែលកាត់បន្ថយយានយន្តជាសហគមន៍ដែលបន្ថយការពឹងផ្អែកទៅលើយានយន្តឯកជន ហើយផ្តល់ជាអាទិភាពទៅលើ លំហសម្រាប់អ្នកថ្មើរជើង មធ្យោបាយដឹកជញ្ជូនសាធារណៈដែលប្រើពេលតិច និងជម្រើសមធ្យោបាយចល័តផ្សេងៗទៀតជំនួសវិញ។

- Ⓜ **តំបន់លំនៅដ្ឋាន ឬ ផ្លូវសម្រាប់ក្មេងលេង បានកំណត់រួច និងមានជាវិធានការសមស្របសម្រាប់អ្នកថ្មើរជើង អ្នកជិះកង់ និងអ្នករស់នៅក្នុងសហគមន៍ផ្ទាល់ រាប់ទាំងកូនក្មេងផងដែរ។**
- ○ បានរៀបចំល្បឿនចរាចរណ៍ឲ្យល្អប្រសើរសម្រាប់ ផ្លូវធំ (ផ្លូវមហាវិថី ផ្លូវជាតិ)។
- ○ បានគ្រប់គ្រង ឬដាក់កម្រិត តម្រូវការចំណតនៅតាម ស្ថាននីយ៍ចល័តភាពផ្សេងៗ។
- ○ កំណត់ផ្លូវពហុមធ្យោបាយ ដោយដាក់ល្បឿនអតិបរមាត្រឹម ៥km/h នៅក្នុងតំបន់លំនៅឋាន ឬតំបន់ស្នាក់នៅ។
- ○ កន្លែងចតរួមនៅក្នុងខណ្ឌទាំងមូលបានគិតបញ្ចូលទៅក្នុងសហគមន៍ និងបន្ថយកន្លែងចតឯកជនបាន ២៥% ។ ដូច្នេះកន្លែងចតមានប្រមាណ ០.៧៥ ក្នុងមួយលំនៅឋាន។
- Ⓣ បរិមាណជាមធ្យមនៃចំណតរថយន្ត គឺក្រោម < ០.៥ ក្នុងមួយលំនៅឋាន ជម្រើសនានា គឺត្រូវបានផ្តល់សម្រាប់ការធ្វើដំណើរពីផ្ទះទៅចំណតរថយន្ត៖ ឧទាហរណ៍៖ ចំណតសម្រាប់ ម៉ូតូ កង់ជាដើម។

សម្រាប់ព័ត៌មានបន្ថែម៖
ឧបករណ៍បរិវត្តកម្ម B4P
០២.៣
សេចក្តីណែនាំអំពី
ការចល័តក្នុងទីក្រុង
ប្រកបដោយចីរភាព



# ការការពារអាកាសធាតុ និងលំហូរថាមពល

គោលដៅនៃលក្ខខណ្ឌវិនិច្ឆ័យការការពារអាកាសធាតុ និងការប្រើប្រាស់ថាមពលគឺដើម្បីកាត់បន្ថយបម្រែបម្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការបំភាយឧស្ម័ន យុទ្ធសាស្រ្តសេដ្ឋកិច្ចចក្រា និងការសន្សំសំចៃធនធាន។ ចំណុចនេះគឺ ផ្ដល់អាទិភាពធំទៅលើថាមពលកកើតឡើងវិញ និងការអនុវត្តបែបចីរភាពក្នុងតំបន់ប្រជុំជនថ្មីៗនៃរាជធានីភ្នំពេញដែលផ្ដល់ជាមូលដ្ឋានមួយ សម្រាប់ការអភិវឌ្ឍន៍កាបូនទាប និងជួយរួមចំណែកដល់គោលដៅ កាត់បន្ថយការបំភាយនៃឧស្ម័នកាបូនរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០៣០។

**រូបភាពទី១០៖** រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.

## ចំណុចទាក់ទង

១. **កាត់បន្ថយបម្រែបម្រួលអាកាសធាតុ៖** កាត់បន្ថយការបំភាយឧស្ម័នបំពុល ដើម្បីបន្ថយកំដៅផែនដី។

២. **ការប្រើធនធាន ដោយសន្សំសំចៃ៖** សហគមន៍ចក្រាជួយកាត់បន្ថយកាកសំណល់ និងជួយសន្សំសំចៃការប្រើប្រាស់ធនធានផ្សេងៗ។

៣. **យុទ្ធសាស្រ្តគ្រប់គ្រងថាមពល៖** ការប្រើប្រាស់ថាមពលដែលមានចីរភាពគឺធានាឲ្យបរិស្ថានទីក្រុងមួយដែលស្អាត ធន់ និងមិនប៉ះពាល់បរិស្ថាន។



M *អប្បបរមា*
T *គោលដៅ*

## អគារដែលសន្សំសំចៃថាមពល |

អគារដែលសន្សំសំចៃថាមពល គឺជាអគារដែលរៀបចំ និងសាងសង់ឡើងដោយមានលក្ខណៈសម្បត្តិផ្សេងៗ ដើម្បីបន្ថយការប្រើប្រាស់ថាមពល។ អគារទាំងនេះមានបញ្ចូលអ៊ីសូឡង់កាត់បន្ថយកំដៅ ម៉ាស៊ីនត្រជាក់ និងប្រព័ន្ធទឹកក្ដៅ ដែលសន្សំសំចៃ។ គំនិតក្នុងការរៀបចំអគារនោះដែរក៏បានពិចារណាទុកក្នុងការធ្វើសមាហរណកម្ម ប្រភពថាមពលចីរភាពដែលមានដូចជា ថាមពលសូឡា ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើ ប្រភពថាមពលដែលមិនអាចកកើតឡើងវិញបាន និងការប៉ះពាល់បរិស្ថាន។

- (M) បានអនុវត្តយុទ្ធសាស្រ្តរចនាអកម្មដោយប្រើខ្យល់ និងពន្លឺធម្មជាតិ ដើម្បីកាត់បន្ថយតម្រូវការកង្ហារ និងម៉ាស៊ីនត្រជាក់
- បានដាក់បញ្ចូលឧបករណ៍ប្រើប្រាស់អគ្គិសនីតិចចូលទៅក្នុងអគារ ឧទាហរណ៍៖ ឧបករណ៍ជួយឲ្យត្រជាក់
- បានធ្វើ អ៊ីសូឡង់កម្ដៅរបស់អគារ ឲ្យល្អជាងមុន
- បានដាក់បញ្ចូលឧបករណ៍ជួយឲ្យត្រជាក់ដែលមិនសូវប៉ះពាល់បរិស្ថានចូលទៅក្នុងអគារ ឧទាហរណ៍៖ ទូរទឹកកកធម្មជាតិ
- ការរៀបចំអគារដោយបានគិតទុកពីការធ្វើសមាហរណកម្ម ប្រភពថាមពលកកើតឡើងវិញ នៅថ្ងៃអនាគត ឧទាហរណ៍៖ ផ្ទាំងសូឡា
- កាត់បន្ថយបានយ៉ាងតិច ៣០% នៃតម្រូវការថាមពលសរុបក្នុងមួយឆ្នាំ បើធៀបទៅនឹងអគារដែលមានមុខងារ និងទំហំស្រដៀងគ្នា
- (T) អគារនានាៗបង្កើតថាមពលខ្លួនឯងបាន ១០០% នៃតម្រូវការរបស់ខ្លួន

## សហគមន៍ ដែលសន្សំសំចៃថាមពល |

សហគមន៍ដែលសន្សំសំចៃថាមពល គឺមានការធ្វើសមាហរណកម្ម ការរៀបចំដោយចីរភាពប្រភពថាមពលដែលកកើតឡើងវិញ និងបច្ចេកវិទ្យាដែលកាត់បន្ថយការប្រើប្រាស់ថាមពល និងដាក់បញ្ចូលប្រភពថាមពលចីរភាព ដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាន។

- (M) បានប្រើយុទ្ធសាស្រ្ត រចនាអកម្ម ដោយប្រើខ្យល់ និងពន្លឺធម្មជាតិ ដើម្បីកាត់បន្ថយតម្រូវការ កង្ហារ ឬម៉ាស៊ីនត្រជាក់ ឧទាហរណ៍៖ បានអនុវត្តអនុសាសន៍ ដែលឆ្លើយតបទៅនឹងអាកាសធាតុ
- បានដាក់បញ្ចូលឧបករណ៍ប្រើអគ្គិសនីតិច ឧទាហរណ៍៖ ភ្លើងដាក់តាមផ្លូវដែលមានភាពសន្សំសំចៃ
- (T) មានដាក់ ម៉ាស៊ីនត្រជាក់ មិនសូវប៉ះពាល់បរិស្ថាន បញ្ចូលទៅក្នុង កម្រិតសហគមន៍ ឧទាហរណ៍៖ ប្រព័ន្ធក្ដៅត្រជាក់ជាតំបន់ដែលសន្សំសំចៃ

## ការរចនាដោយគិតពីវដ្ដជីវិតនៃអគារ |

ស្ថាបត្យកម្ម ដែលគិតពីវដ្ដជីវិតនៃអគារ គឺមានការធ្វើសមាហរណកម្មគោលការណ៍ចីរភាពតាំងពីការរៀបចំដំបូង ពេលសាងសង់ ពេលដំណើរការ និងពេលដែលអគារនោះត្រូវកម្ទេចចោល។ ចំណុចនេះផ្ដោតធំទៅលើការកាត់បន្ថយការប៉ះពាល់បរិស្ថាន និងការប្រើធនធានឲ្យមានភាពសន្សំសំចៃ ហើយមានប្រសិទ្ធភាពខ្ពស់ គ្រប់ដំណាក់កាលនៃវដ្ដជីវិតអគារនេះ។

- (M) **កាត់បន្ថយបាន ២០% នៃបេតុង ដែក និងខ្សាច់ បើធៀបទៅនឹងអគារដែលមានមុខងារ និងទំហំស្រដៀងគ្នា ហើយបានធ្វើការគណនា និងធ្វើការបញ្ជាក់រួចជាស្រេច**
- ២៥% នៃគ្រឿងសំណង់ប្រើគឺផលិតក្នុងតំបន់
- ២៥% នៃគ្រឿងសំណង់ប្រើគឺវត្ថុធាតុដើម ដែលអាចកកើតឡើងវិញបាន និងមានជាការធានា ឬផ្គត់ផ្គង់មកដោយស្របច្បាប់ និងអាចបញ្ជាក់បាន
- ២៥% នៃគ្រឿងសំណង់ប្រើគឺអាចកែឆ្នៃ ឬប្រើប្រាស់ឡើងវិញបាន
- ៨០% នៃគ្រឿងសំណង់អគារ គឺអាចយកមកវិញបានក្រោយពេលប្រើប្រាស់រួច
- ៨០% នៃគ្រឿងសំណង់អគារ គឺអាចយកមកប្រើជាគ្រឿងសំណង់ជាថ្មីវិញបាន
- (T) ការរចនាអគារបានបំពេញគ្រប់ ឬលើសពីលក្ខខណ្ឌខាងលើ

## សហគមន៍ចក្រា |

សហគមន៍ចក្រា គឺជាសហគមន៍ណាដែលទទួលយកគោលការណ៍នៃសេដ្ឋកិច្ចចក្រា ដោយកាត់បន្ថយការបង្កើតកាកសំណល់។ សហគមន៍ទាំងនោះឲ្យតម្លៃទៅលើ ការកែច្នៃនិងប្រើប្រាស់ឡើងវិញ និងការអនុវត្តបែបចីរភាពផ្សេងៗទៀត ដែលបង្កើតបានជាសហគមន៍ដែលឆ្ពោះទៅរកប្រព័ន្ធសេដ្ឋកិច្ចចក្រា។

- (M) បានកំណត់វិធានការគ្រប់គ្រងកាកសំណល់សម្រាប់ កំឡុងពេលការសាងសង់
- បានបញ្ចូលកន្លែងប្រមូលសម្រាម និងទុកកន្លែងសម្រាប់បម្លែងសម្រាមសរីរាង្គ ទៅជាជីកំប៉ុស
- (T) បានធ្វើជាកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសម្រាម និងកាលវិភាគប្រមូលសម្រាមសម្រាប់សហគមន៍

សម្រាប់ព័ត៌មានបន្ថែម៖
ឧបករណ៍បរិវត្តកម្ម B4P

០២.៤
សេចក្ដីណែនាំអំពី
ការការពារអាកាសធាតុ
និងលំហូរថាមពល

## *លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖

- បានគណនាទុកមុននូវគម្រោងថវិកាថាមពលនៅកម្រិតអគារ និងសហគមន៍ទាំងមូលក្នុងដំណាក់កាលរចនាដំបូង
- ហេតុផលនៃវដ្ដជីវិត(LC-) របស់អគារ និងសហគមន៍ទាំងមូល ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្រិតនៃការប៉ះពាល់ទៅលើបរិស្ថានតាំងពី៖ ការរចនា ការសាងសង់ និងចុងជីវិតនៃអគារ ឬសហគមន៍នោះ។
- ៥០% នៃគ្រឿងសំណង់ទាំងអស់ មានភាពប៉ះពាល់តិចទៅលើបរិស្ថាន ក្នុងមួយវដ្ដជីវិតរបស់វា។



លក្ខណៈវិនិច្ឆ័យ ០១.០
សេចក្ដីណែនាំ ០២.៤




# បរិយាប័ន្នសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន

រូបភាពទី១១៖ រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.

គោលដៅលក្ខខណ្ឌវិនិច្ឆ័យបរិយាប័ន្នសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន គឺដើម្បីធានាសមភាពក្នុងការទទួលបានឱកាស និងសេវាកម្មផ្សេងៗ ចំពោះអ្នករស់នៅក្នុងសហគមន៍ ដែលមាន-ជីវភាពផ្សេងៗគ្នា ដើម្បីជំរុញឲ្យមានភាពជាកម្មសិទ្ធិក្នុងសហគមន៍។ ដោយគាំទ្រអាជីវកម្មក្នុងសហគមន៍ និងលើកស្ទួយឲ្យមានភាពធន់នៃសេដ្ឋកិច្ច លក្ខខណ្ឌវិនិច្ឆ័យនេះ គឺគ្រោង-ដើម្បីជំរុញសហគមន៍មួយ ដែលសមធម៌មានការភ្ជាប់ប្រាស្រ័យ និងប្រកបដោយចីរភាព។

## ចំណុចទាក់ទង

១. **សុខដុមនីយកម្មសហគមន៍៖** បរិយាប័ន្នសង្គមគឺជំរុញឲ្យមាននូវ ភាពជាកម្មសិទ្ធិ និងភាពចម្រុះនៃអ្នករស់នៅក្នុងសហគមន៍។

២. **ភាពធន់នៃសេដ្ឋកិច្ច៖** សេដ្ឋកិច្ចដែលរីកចម្រើនគឺជួយលើកស្ទួយការអភិវឌ្ឍន៍មួយដែលធន់ និងមានចីរភាព។

៣. **គុណភាពជីវិតដែលប្រសើរជាងមុន៖** បរិយាប័ន្នសង្គម និងការគាំទ្រដោយសេដ្ឋកិច្ចសហគមន៍គឺជាការចូលរួមចំណែកទៅដល់បរិស្ថានទីក្រុងដែលងាយស្រួលរស់នៅ មានការភ្ជាប់ប្រាស្រ័យ និងមានភាពរស់រវើក។

M អប្បបរមា
T គោលដៅ

## លំនៅឋានតម្លៃសមរម្យ |

លំនៅឋានតម្លៃសមរម្យ គឺសំដៅទៅលើលំនៅឋាន ដែលមានតម្លៃមួយដែលគ្រួសារ ឬបុគ្គលដែលមានជីវភាពទាប ឬមធ្យមមានលទ្ធភាពទិញ ដោយផ្តល់ជាជម្រក ដែលមានសុវត្ថិភាព និងសន្តិសុខ។

*មានទំនាក់ទំនងជាមួយនឹងលក្ខខណ្ឌវិនិច្ឆ័យ ការផ្សារភ្ជាប់សហគមន៍ និងទីក្រុងជាមួយជំពូកសមាហរណកម្មការរៀបចំគម្រោងអភិវឌ្ឍន៍។

- M **១០% នៃលំនៅឋានបានគ្រោងជាលំនៅឋានតម្លៃសមរម្យ**
- ○ បរិក្ខាររបស់សហគមន៍គឺអាចប្រើប្រាស់បានទាំងអស់គ្នា* (N)
- ○ ហេដ្ឋារចនាសម្ព័ន្ធសង្គម និងអាជីវកម្មអាចប្រើប្រាស់បានទាំងអស់គ្នា* (N)
- T ២០% នៃលំនៅដ្ឋានបានគ្រោងជាផ្ទះតម្លៃសមរម្យ និងគ្រប់បរិក្ខារ ឬហេដ្ឋារចនាសម្ព័ន្ធទាំងអស់អាចប្រើប្រាស់បានទាំងអស់គ្នា

## ផ្លូវដ៏មមាញឹក |

ផ្លូវសកម្ម ឬផ្លូវអាជីវកម្មមមាញឹក គឺជាផ្លូវដែលមានបណ្តុំអាជីវកម្ម ហាង និងសេវាកម្មផ្សេងៗច្រើន។ ផ្លូវប្រភេទនេះជួយបង្កើនសកម្មភាព អ្នកថ្មើរជើង ការប្រាស្រ័យទាក់ទងគ្នា និងសកម្មភាពអាជីវកម្មដែលផ្តល់ជាភាពរស់រវើក ជួយធ្វើឲ្យបរិយាកាសរស់នៅក្នុងទីក្រុងកាន់តែប្រសើរជាងមុន។

- M **អនុសាសន៍ទាក់ទងនឹងផាសុកភាពផ្លូវកាយទៅលើអាកាសធាតុ ដែលដាក់បញ្ចូលក្នុងការណែនាំ ការរៀបចំដែលឆ្លើយតបទៅនឹងអាកាសធាតុ ឧទាហរណ៍៖ ការផ្តល់ម្លប់ ការផ្តល់ខ្យល់ចេញចូល ការការពារភ្លៀង។ល។ ត្រូវបានយកមកអនុវត្ត ដើម្បីលើកកម្ពស់បទពិសោធន៍របស់អ្នកដែលមកប្រើលំហសាធារណៈ ឧទាហរណ៍៖ ការរៀបចំជាន់ផ្ទាល់ដី។**
- ○ ២០% នៃទំហំផ្ទៃក្រឡាកម្រាលសរុប (GFA) ត្រូវបានកំណត់សម្រាប់មុខងារអាជីវកម្ម
- ○ ៥០% នៃផ្ទៃមុខអគារមានសមាសធាតុសកម្ម៖ វេរ៉ង់ដា ទេរ៉ាស់
- T បានបំពេញគ្រប់ ឬលើសពីលក្ខខណ្ឌខាងលើ

## ការពង្រឹងសេដ្ឋកិច្ចតំបន់ |

សេដ្ឋកិច្ចតំបន់ គឺសំដៅលើសកម្មភាពអាជីវកម្មផ្សេងៗក្នុងសហគមន៍ណាមួយ។ ចំណុចនេះផ្តោតធំទៅលើការផលិត និងប្រើប្រាស់ផលិតផល ឬសេវាកម្មក្នុងសហគមន៍ផ្ទាល់ ដែលជំរុញឲ្យមានចីរភាពសហគមន៍ និងមានភាពធន់។

- M **ទីធ្លាសាធារណៈបានរៀបចំកម្មវិធីសម្រាប់សាធារណៈជន ក្នុងមួយខែម្តង៖ ផ្សារកសិករ កម្មវិធីប្រចាំឆ្នាំ ចូលឆ្នាំខ្មែរ**
- ○ ហាង និងភោជនីយដ្ឋាននានាជួយចូលរួមលើកស្ទួយសេដ្ឋកិច្ចសហគមន៍៖ ការដាក់បង្ហាញផលិតផល ឬគ្រឿងផ្សំដែលផលិត ឬដាំដុះក្នុងសហគមន៍
- T បានគ្រោងទុកនូវ កន្លែងជួលតម្លៃសមរម្យ ឬអត់គិតថ្លៃ សម្រាប់ធុរកិច្ចថ្មី ឬសិប្បកម្មក្នុងតំបន់

## ភាពចម្រុះនៃសង្គម |

ភាពចម្រុះនៃសង្គម គឺជាការច្របាច់បញ្ចូលអ្នករស់នៅ ដែលមានវប្បធម៌ និងជីវភាពផ្សេងៗគ្នាចូលទៅក្នុងសហគមន៍មួយ។ ចំណុចនេះជួយលើកកម្ពស់សុខដុមនីយកម្មសង្គម បរិយាប័ន្នសង្គម ការយល់ចិត្តគ្នា និងបានចងក្រងបទពិសោធន៍ដ៏សម្បូរបែប។

- M **បានដាក់បញ្ចូលរួចជាស្រេចនូវ អគារពហុមុខងារ និងជម្រើសលំនៅឋាន សម្រាប់មនុស្ស ឬគ្រួសារដែលមានចំណូលផ្សេងៗគ្នា**
- ○ បានដាក់បញ្ចូលរួចជាស្រេចនូវ អគារលំនៅឋានរួមនឹងអាជីវកម្ម (ផ្ទះល្វែង ផ្ទះអាជីវកម្ម)
- ○ បានដាក់បញ្ចូលរួចជាស្រេចនូវ អគារលំនៅដ្ឋានរួមនឹងការិយាល័យធ្វើការ
- T បានដាក់បញ្ចូលរួចជាស្រេចនូវប្រភេទអគារ ដែលមិនរើសអើងដល់ជនពិការ

### *លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖

- ○ តម្លៃវដ្តជីវិត (LCC) ជាឧបករណ៍ក្នុងការរចនា
- ○ ណែនាំអំពី គម្រោងផ្តួចផ្តើមសេដ្ឋកិច្ចនៃការចែករំលែក៖ ការចែករំលែកឧបករណ៍ប្រើប្រាស់ បណ្ណាល័យកន្លែងបរិច្ចាគ

សម្រាប់ព័ត៌មានបន្ថែម៖
ឧបករណ៍បរិវត្តកម្ម B4P
០២.៥
សេចក្តីណែនាំអំពី
បរិយាប័ន្នសង្គម
និងសេដ្ឋកិច្ចមូលដ្ឋាន




# អភិបាលកិច្ច និងការចូលរួម

**រូបភាពទី១២៖** រូបភាពក្រាហ្វិកគូរដោយ Uddam Pen, Prosob Media, Phnom Penh.

គោលដៅនៃលក្ខខណ្ឌវិនិច្ឆ័យ អភិបាលកិច្ច និងការចូលរួម គឺដើម្បីជំរុញឲ្យមានបរិយាប័ន្ន តម្លាភាព និងគណនេយ្យភាពនៅគ្រប់ដំណាក់កាលនៃការសម្រេចចិត្តគ្រប់កម្រិត (រដ្ឋបាលទីក្រុង ក្រុមធ្វើផែនការ និងអ្នកទទួលផល)។ ដោយលើកទឹកចិត្តការរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់រួមមានអ្នកអភិវឌ្ឍន៍អចលនទ្រព្យឯកជន និងអ្នកទទួលផល លក្ខខណ្ឌវិនិច្ឆ័យនេះមានគោលបំណងក្នុងការបង្កើតវិធីសាស្ត្រសហការមួយ ដែលស្ថាបនារាជធានីភ្នំពេញឲ្យក្លាយជាទីក្រុងមួយ ដែលមានចីរភាព និងបរិស្ថានល្អ។

## ចំណុចទាក់ទង

១. **ការសម្រេចចិត្តដោយមានបរិយាប័ន្ន៖** លើកទឹកចិត្តឲ្យមានទស្សនវិស័យ ដែលចម្រុះនៅក្នុងការធ្វើនគរូបនីយកម្ម។

២. **តម្លាភាព និងគណនេយ្យភាព៖** បង្កើតអោយមានជំនឿទុកចិត្តដោយអោយមានការចូលរួមពីប្រជាជនក្នុងការសម្រេចចិត្តផ្សេងៗ។

៣. **គោលនយោបាយដែលមានការឆ្លើយតប៖** ធានាថាការអភិវឌ្ឍន៍ទីក្រុងគឺស្របទៅនឹងតម្រូវការ និងតម្រូវការរបស់សហគមន៍។



Ⓜ *អប្បបរមា*
Ⓣ *គោលដៅ*

### ការពាក់ព័ន្ធ និងការចូលរួមពីសហគមន៍ |

ការពាក់ព័ន្ធ និងការចូលរួមពីសហគមន៍ គឺធានាការចូលរួមជាសកម្មពីបុគ្គលនានា នៅក្នុងរឿងរ៉ាវសហគមន៍ ការសម្រេចចិត្តផ្សេងៗ និងគំនិតផ្តួចផ្តើមសហការណ៍។ ចំណុចនេះ ជួយជំរុញឲ្យមានភាពជាកម្មសិទ្ធិ-បង្កើនភាពអង់អាចដល់អ្នករស់នៅក្នុងសហគមន៍ និងពង្រឹងភាពជិតស្និតនៅក្នុងសហគមន៍។

- Ⓜ **មានកម្មវិធីផ្តល់ព័ត៌មានកំឡុងពេលរចនា ឬសាងសង់**
- ○ មានកម្មវិធីពិគ្រោះសំណេះសំណាល ឬសិក្ខាសាលាកំឡុងពេលរៀបចំ ឬសាងសង់
- Ⓣ កម្មវិធីចូលរួមពីសាធារណៈ និងសិក្ខាសាលាកសាងផែនការ ប្រព្រឹត្តឡើងកំឡុងពេលរៀបចំគម្រោង

### ការរៀបចំផែនការសមាហរណកម្ម |

ការរៀបចំផែនការនគរូបនីយកម្មសមាហរណកម្ម គឺពាក់ព័ន្ធទៅនឹងការសម្របសម្រួលសមាសធាតុផ្សេងៗ នៃការអភិវឌ្ឍន៍ទីក្រុងដែលរួមមានមធ្យោបាយដឹកជញ្ជូន លំនៅឋាន និងលំហសាធារណៈ។ ចំណុចនេះដែរគឺផ្តោតលើការបង្កើតបរិស្ថានទីក្រុង ដែលដំណើរការល្អ មានភាពស៊ីសង្វាក់គ្នា ហើយប្រកបដោយចីរភាព។

- Ⓜ **កំណត់ជាក្រុមរចនាពហុជំនាញមួយ និងរៀបចំជាសិក្ខាសាលាអន្តរកម្មយ៉ាងតិចមួយក្នុងដំណាក់កាលមុនរៀបចំគម្រោង**
- ○ សេណារីយ៉ូ និងជម្រើសនានាត្រូវបានបង្កើតឡើង និងវាយតម្លៃរួចជាស្រេច
- ○ កំណត់ជា ក្រុមរចនាពហុជំនាញមួយ និងរៀបចំជាសិក្ខាសាលាពិគ្រោះរចនាគម្រោងឲ្យបានយ៉ាងតិចបីដងនៅក្នុងដំណាក់កាលមុនរចនាដំណាក់រចនា និងដំណាក់កាលសាងសង់។
- Ⓣ ក្រុមរចនាពហុជំនាញបានកំណត់ពេលធ្វើកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់គម្រោង និងការពិភាក្សាបច្ចេក-ទេសធម្មតា (ឧទាហរណ៍ jour-fix) ដើម្បីពិភាក្សាស្តីពីការកសាងផែនការ និងសាងសង់

### របៀបរស់នៅដោយចីរភាព |

របៀបរស់នៅដោយចីរភាព គឺពាក់ព័ន្ធទៅនឹងការសម្រេចចិត្ត និងអនុវត្តដោយមានការយល់ដឹង ដែលជួយកាត់បន្ថយការប៉ះពាល់បរិស្ថានផ្តោតធំទៅលើការសន្សំសំចៃធនធាន និងចូលរួមចំណែកដល់ការរស់នៅរបស់បុគ្គល ឬសហគមន៍ ដែលប្រកបដោយតុល្យភាព និងមានទំនួលខុសត្រូវទៅលើបរិស្ថាន។

- Ⓜ **បានបង្កើតការផ្សព្វផ្សាយសម្រាប់លើកស្ទួយការរស់នៅបែបចីរភាព**
- ○ បានរៀបចំជា យុទ្ធនាការផ្សព្វផ្សាយអំពីការចែក និងកាត់បន្ថយកាកសំណល់
- Ⓣ បានកំណត់ស្តង់ដារចែកកាកសំណល់ សម្រាប់ការប្រមូលសំណល់ពីសហគមន៍

***លក្ខខណ្ឌវិនិច្ឆ័យ បន្ថែមជាជម្រើសបន្ទាប់បន្សំរួមមាន៖**

- ○ ជួយគាំទ្រការបង្កើត គណៈកម្មាធិការសហគមន៍
- ○ ជួយគាំទ្រយុទ្ធនាការកែច្នៃសំណល់ ឬសកម្មភាពជួយបរិស្ថាន

សម្រាប់ព័ត៌មានបន្ថែម៖
ឧបករណ៍បរិវត្តកម្ម B4P
០២.៦
សេចក្តីណែនាំអំពី
អភិបាលកិច្ច
និងការចូលរួម

# V មូលដ្ឋានគ្រឹះនៃសន្ទស្សន៍សម្រាប់ការរៀបចំ

## និយមន័យ នៃក្រឡាផ្ទៃសម្រាប់រៀបចំសហគមន៍

| | |
|---|---|
| *ផ្ទៃដីឡូតិ៍សរុប (GSA)* | ដីដែលចង់អភិវឌ្ឍន៍ ឬដីដែលអភិវឌ្ឍន៍ហើយ ដែលរួមមានការអភិវឌ្ឍន៍សាធារណៈ និងចំណតផ្ទៃបៃតង និងកន្លែងផ្ទុកឥវ៉ាន់។ |
| *ផ្ទៃក្រឡាជាក់ស្តែង (NSA)* | ផលបូកនៃផ្ទៃក្រឡាអគារ ឬផ្ទៃក្រឡាដែលយកមកអភិវឌ្ឍន៍នៅក្នុងដីឡូតិ៍។ |
| *លំហបៃតងឯកជន (PRGS)* | ផ្ទៃសួនច្បារផ្ទះ តេរ៉ាស់ សួន សួនលើដំបូល។ |

## និយមន័យផ្ទៃសម្រាប់អគារ

| | |
|---|---|
| *ផ្ទៃក្រឡាកម្រាលសរុប (GFA)* | ផ្ទៃក្រឡាកម្រាលសរុប (GFA) គឺកំណត់ជាផ្ទៃសរុបជាន់ក្រោម និងលើដីនៃអគារទាំងអស់ (រាប់ទាំងឡៅតឿ និងជាន់លើបន្ទាប់) ហើយក៏រាប់ទាំងជាន់ក្រោមដី ដែលប្រើប្រាស់ (ឧទាហរណ៍៖ធ្វើអាជីវកម្ម ផ្ទះបន្ថែម ឬផ្ទះទីពីរ) និងកន្លែងទុកបរិក្ខារផ្សេងៗ ប៉ុន្តែមិនរាប់ផ្ទៃ ដែលនៅខាងក្រៅអគារនោះឡើយដូចជាវេរ៉ង់ដា និងតេរ៉ាស់។ |
| *ប្រភាគក្រឡាផ្ទៃបាតអគារ (BCR)* | ប្រភាគក្រឡាផ្ទៃបាតអគារ (BCR) គឺជាភាគរយនៃផ្ទៃដីឡូតិ៍ដែលគ្របដណ្តប់ដោយបាតអគារ ដែលដកផ្ទៃបើកចំហដូចជា សួនច្បារ ឬចំណត។ ចំណុចនេះជួយគ្រប់គ្រងការប្រើប្រាស់ដី និងជួយរក្សា ផ្ទៃដីដែលយកមកសាងសង់ដោយមានតុល្យភាព និងរក្សាផ្ទៃជម្រាបទឹក។ |
| *ផ្ទៃសរុបអគារ (FAR)* | ផ្ទៃសរុបអគារ (FAR) គឺជាឧបករណ៍ធ្វើច្បាប់បែងចែកតំបន់ ដែលប្រើនៅក្នុងការធ្វើនគររូបនីយកម្ម ដើម្បីគ្រប់-គ្រងការប្រើប្រាស់ដី។ ផ្ទៃសរុបអគារ (FAR) គឺបានដោយការវាស់ ផ្ទៃសរុបនៃជាន់អគារទាំងអស់ធៀបទៅនឹងផ្ទៃដីឡូតិ៍ដែលយកមកសាងសង់អគារនោះ ដែលមានឥទ្ធិពលទៅលើដង់ស៊ីតេ និងទំហំអគារនៅក្នុងតំបន់មួយ។ កត្តាលេខនេះ ក៏មានពាក្យមួយទៀតហៅថា Floor Space Index (FSI) ដែលមានន័យដូចទៅនឹងផ្ទៃសរុបអគារ (FAR) ឬ Floor Area Ration (FAR)។ |
| ដានអគារ *(BFA)* | ដានអគារសរុបតាមប្លង់ គឺគិតពីព្រំជញ្ជាំងអគារពីខាងក្រៅ និងសសរទាំងអស់។ |

## ការកំណត់

| | |
|---|---|
| *ចម្ងាយដើរបាន* | គឺសំដៅទៅលើចម្ងាយដែលអាចថ្មើរជើង ដោយមានផាសុកភាពបាន។ ចម្ងាយជាមធ្យម ដែលដើរបានក្នុងទីក្រុង សម្រាប់មនុស្សភាគច្រើនគឺក្នុងរយៈចម្ងាយ ៤០០ម ទៅ៨០០ម ដែលប្រើរយៈពេលប្រហាក់ប្រហែលពី ៥ ទៅ១៥នាទី ក្នុងការដើរ ឬក្នុងល្បឿនជាមធ្យម ១.៤២m/s ។ |
| *តំបន់ពហុមុខងារ* | ល្បាយនៃមុខងារផ្សេងៗគ្នា (លំនៅឋាន អាជីវកម្ម ការកម្សាន្ត វប្បធម៌ ការអប់រំ) ក្នុងខណ្ឌដីសាងសង់ ឬក្នុងអគារ។ |





## ការកំណត់ (បន្ត)

| | |
|---|---|
| *សហគមន៍បិទរបង ឬបុរី* | សហគមន៍បែបនេះជាតំបន់លំនៅដ្ឋានដែលបិទដោយធាតុរឹងផ្សេងៗដែលមានដូចជាជញ្ជាំង ឬរបង និងមានកន្លែងចេញចូល ដែលមានការគ្រប់គ្រងតឹងរឹង។ សហគមន៍ទាំងនេះ តែងតែមានលក្ខណៈសម្បត្តិដូចជាសន្តិសុខចាំឃ្លាំមើល កាមេរ៉ាសុវត្ថិភាព និងការដាក់កម្រិត អ្នកក្រៅសហគមន៍ពីការចេញចូល។ |
| *ជាន់សកម្មផ្ទាល់ដី* | គឺសំដៅទៅលើ កន្លែងជាន់ផ្ទាល់ដីនៃអគារ ដែលរៀបចំឡើងដើម្បីទាក់ទាញអ្នកថ្មើរជើង និងជំរុញឲ្យមានសកម្មភាពទីក្រុងអោយមានភាពរស់រវើក។ ជាន់នេះតែងរួមបញ្ចូល ផ្ទៃមុខអគារដែលមើលឃើញទៅមក (ឧទាហរណ៍ ដាក់កញ្ចក់ ឬបង្អួច) មានជាហាង កន្លែងពិសារនៅខាងក្រៅ ឬលំហ ដែលធ្វើឡើងសម្រាប់សហគមន៍ ដែលជួយជំរុញឲ្យមានការឆ្លើយឆ្លងគ្នា និងការចេញចូល។ |
| *លំហសាធារណៈ (PS)* | ជាកន្លែង ដែលអាចមកប្រើប្រាស់បានដោយសេរី អត់គិតថ្លៃ ពីសំណាក់សាធារណៈជនគ្រប់ពេលវេលា និងភាគច្រើនគ្រប់គ្រងថែទាំដោយ រដ្ឋបាលក្រុង (តំបន់មធ្យោបាយដឹកជញ្ជូនសាធារណៈ លំហបើចំហ និងលំហបៃតង ឬទីធ្លាសាធារណៈផ្សេងៗ)។ |
| *លំហបៃតងសាធារណៈ (PGS)* | ជាទូទៅគឺជាលំហបៃតងដែលប្រើប្រាស់បានដោយសាធារណៈ ដែលជួយឲ្យមានលំនឹងអេកូឡូស៊ី ធ្វើឲ្យអាកាសធាតុប្រសើរជាងមុន ផ្តល់ជាការកម្សាន្ត និងសុខភាពទៅដល់ប្រជាជន ហើយក៏មានជាការលើកតម្កើងវប្បធម៌ និងសកម្មភាពកីឡាផងដែរ។ តំបន់ផ្ទៃទឹក និងកន្លែងកម្សាន្តក៏ត្រូវបានកំណត់ជាលំហបៃតង (បើយោងតាម DGNB) ។ បើសិនលំហបៃតងនោះ ជាកម្មសិទ្ធឯកជនប៉ុន្តែអាចប្រើបានដោយសាធារណៈនោះ ក៏អាចរាប់បញ្ចូលទៅក្នុងការគណនាដូចគ្នា។ ឧទាហរណ៍ ជាសួនច្បារធំមួយនៅខាងមុខក្រុមហ៊ុនឯកជន។ |
| *លំហបៃតងឯកជន (PRGS)* | ផ្ទៃសួនច្បារនៅផ្ទះ តេរ៉ាស់ សួន សួនច្បាលើដំបូល។ |
| *តំបន់ដែលគ្របដណ្តប់ដោយដើមឈើ* | ជាចំណាត់ថ្នាក់ដីដែលកំណត់ឡើង ដោយមានវត្តមាន ដើមឈើដុះញឹក ដែលភាគច្រើនបង្កើតបានទៅជាព្រៃឈើ។ |
| *តំបន់ដែលគ្របដណ្តប់ដោយរុក្ខជាតិ* | ជាចំណាត់ថ្នាក់ដី ដែលកំណត់ឡើង ដោយមានវត្តមាន រុក្ខជាតិ ដែលរួមមានទាំង ដើមឈើ គុម្ពឈើ ស្មៅ និងទម្រង់រុក្ខជាតិផ្សេងៗទៀត។ ពាក្យនេះភាគច្រើនសំដៅទៅលើរុក្ខជាតិទូទៅ ដែលមិនកំណត់ប្រភេទជាក់លាក់។ |
| *ការធ្វើដំណើរល្បឿនយឺត* | ពាក្យនេះសំដៅទៅលើមធ្យោបាយដឹកជញ្ជូន ដែលនៅក្នុងល្បឿនមួយសម្រាប់ជិះកម្សាន្តដូចជា ការដើរ ជិះកង់ ឬមធ្យោបាយដឹកជញ្ជូនដែលមិនប្រើម៉ាស៊ីនផ្សេងៗទៀត។ ចំណុចនេះផ្តោតលើ ការចល័តដោយកម្លាំងមនុស្ស លើកកម្ពស់ការធ្វើចលនារាងកាយ កាត់បន្ថយការប៉ះពាល់បរិស្ថាន និងជំរុញឲ្យទទួលបានបទពិសោធន៍ធ្វើដំណើរមួយដែលសប្បាយ និងមានជាការផ្សារភ្ជាប់ក្នុងសហគមន៍។ |
| *លំហប្រើប្រាស់រួម* | ផ្លូវ ដែលបានរៀបចំឡើងដោយបញ្ចូលនូវ គោលការណ៍ចម្រុះក្នុងការដាក់ ប្រព័ន្ធមធ្យោបាយធ្វើដំណើរផ្សេងៗតាម ដែលអាចធ្វើបានដោយគ្មានការបែងចែក។ ជាទូទៅមិនចាំបាច់មានផ្លាកសញ្ញា និងភ្លើងស្តុប។ |
| *មធ្យោបាយដឹកជញ្ជូនតភ្ជាប់* | ពាក្យនេះមានរួមបញ្ចូលប្រភេទមធ្យោបាយដឹកជញ្ជូនក្រៅផ្លូវការ ដែលបត់បែនបានដូចជាតុកតុក ម៉ូតូឌុប និងប្រភេទឡានវែនតូចៗ។ សេវាកម្មទាំងនេះ ជួយបំពេញចម្ងាយនៅចន្លោះប្រព័ន្ធដឹកជញ្ជូនសាធារណៈ (ឧទាហរណ៍ ធ្វើដំណើរពីកន្លែងចាំឡានក្រុងទៅកន្លែងចាំឡានក្រុងនៃខ្សែមួយទៀត ឬទៅដល់គោលដៅបន្តគៀកនឹងខ្សែឡានក្រុង) ដោយផ្តល់នូវការធ្វើដំណើរចម្ងាយខ្លីៗភ្លាមៗ ក្នុងតម្លៃសមរម្យ។ |
| *តំបន់លំនៅឋាន* | ផ្លូវលំនៅឋាន ដែលរៀបចំឡើងដោយផ្តល់អាទិភាពទៅដល់ សុវត្ថិភាពអ្នកថ្មើរជើង និងអ្នកជិះកង់ដោយទប់ស្កាត់ការជិះកាត់ ឬវៀងតាមផ្លូវនេះ។ ផ្លូវទាំងនេះត្រូវរៀបចំវិធានការរូបវន្តបន្ថយល្បឿនចរាចរណ៍ដូចជាទួលបន្ថយល្បឿន ការបង្រួមផ្លូវ ការរចនាឲ្យទេសភាពបៃតង ដើម្បីបង្កើតជាផ្លូវពហុមធ្យោបាយ ឬផ្លូវរួមសម្រាប់អ្នករស់នៅ កូនក្មេង និងអ្នកមកលេង ដើម្បីមានការប្រាស្រ័យទាក់ទង លេងកម្សាន្ត និងចល័តដោយសុវត្ថិភាព។ |

## ការកំណត់ (បន្ត)

| | |
|---|---|
| *ការរចនាអកម្ម* | វិធីសាស្ត្រក្នុងការរចនា ដោយប្រើប្រាស់សមាសធាតុធម្មជាតិដូចជា ពន្លឺព្រះអាទិត្យ ម្លប់ និងចរន្តខ្យល់ ដែលបង្កើតបានជាបរិស្ថានខាងក្នុង ដែលមានផាសុកភាពដោយប្រើប្រព័ន្ធក្តៅត្រជាក់តិច។ ការរៀបចំរចនាបែបនេះគឺមានបញ្ចូល ទិសនៃអគារ អ៊ីសូឡង់ ចរន្តខ្យល់ និងគ្រឿងសំណង់ ដើម្បីបង្កើនប្រសិទ្ធភាព ការសន្សំសំចៃភ្លើង និងផាសុកភាពផ្លូវកាយអាកាសធាតុ។ យុទ្ធសាស្ត្រអកម្ម គឺមានទិសដៅកាត់បន្ថយការប្រើប្រាស់ថាមពល ចំណាយទឹកភ្លើង និងកាត់បន្ថយការប៉ះពាល់បរិស្ថាននៅក្នុងការសាងសង់ និងដំណើរការអគារ។ |
| *ឧបករណ៍ប្រើប្រាស់ថាមពលតិច* | ឧបករណ៍ផ្សេងៗ ដែលបង្កើតឡើង ដើម្បីដំណើរការដោយប្រើប្រាស់អគ្គិសនីតិច បើធៀបនឹងឧបករណ៍ស្រដៀងគ្នាផ្សេងទៀត។ ឧបករណ៍ទាំងនោះផ្តល់ប្រសិទ្ធភាពជាអតិភាព តាមរយៈបច្ចេកវិទ្យាទំនើបដូចជា ប្រព័ន្ធLED ម៉ូទ័រ ផលិតថាមពលមានប្រសិទ្ធភាព និងប្រព័ន្ធបញ្ជាឆ្លាតវៃ។ តាមរយៈការកាត់បន្ថយនូវតម្រូវការថាមពលនេះ ក៏រួមចំណែកទៅដល់ការកាត់បន្ថយចំណាយដល់អ្នកប្រើប្រាស់ និងកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលពាក់ព័ន្ធ និងការផលិតថាមពល ព្រមទាំងគាំទ្រគោលដៅចីរភាព និងកិច្ចខិតខំប្រឹងប្រែងអភិរក្សថាមពល។ |
| *តម្រូវការថាមពល* | សំដៅលើថាមពលសរុប ដែលត្រូវបំពេញតម្រូវការនៅក្នុងតំបន់ណាមួយដូចជាទីក្រុង តំបន់ ឬប្រទេស ដែលជាតំបន់ លំនៅឋាន អាជីវកម្ម វិស័យឧស្សាហកម្ម និងដឹកជញ្ជូន។ ចំណុចនេះកំណត់ជាតួរលេខការប្រើប្រាស់ថាមពលសរុប ដែលដើរតួរជាសូចនាករក្នុងការធ្វើផែនការប្រើប្រាស់ថាមពល និងការរៀបចំគោលនយោបាយ។ |
| *វត្ថុធាតុដើមដែលកកើតឡើងវិញ* | វត្ថុធាតុដើមដែលយកមកពីប្រភពធម្មជាតិដែលអាច ដុះ ឬកើតឡើងវិញបាននៅពេលក្រោយ តាមរយៈធម្មជាតិផ្ទាល់ ឬការអនុវត្តបែបចីរភាពណាមួយ។ វត្ថុធាតុដើមនេះដូចជាឈើ ឬស្សី និងcork ត្រូវបានប្រមូលមកប្រើប្រាស់ហើយ ដែលធានាថាវាអាចដុះ ឬកើតឡើងវិញនៅពេលក្រោយ ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើធនធានកម្រ និងកាត់បន្ថយការប៉ះពាល់បរិស្ថាន។ |
| *សម្ភារៈដែលមានវិញ្ញាបនបត្រ* | ជាផលិតផល ឬវត្ថុដែលត្រូវបានគេពិនិត្យបញ្ជាក់ឲ្យត្រូវលក្ខខណ្ឌស្តង់ដារ ដែលធ្វើឡើងដោយស្ថាប័នចេញវិញ្ញាបនបត្រឯករាជ្យណាមួយ។ ស្តង់ដារនេះ ភាគច្រើនគ្របដណ្តប់លើកត្តាដូចជាចីរភាព ដំណើរការបៃតង ទំនួលខុសត្រូវសង្គម និងការធ្វើលទ្ធកម្មប្រកបដោយក្រមសីលធម៌ ដែលកត្តាទាំងនេះជួយផ្តល់នូវការធានាគុណភាព និងជួយបំពេញលក្ខខណ្ឌស្តង់ដារផ្សេងៗដែលគេទទួលស្គាល់។ |
| *វត្ថុកែច្នៃឡើងវិញ* | ជាវត្ថុ ឬសម្ភារៈ ដែលទាញចេញពីចរន្តកាកសំណល់ ហើយយកមកផលិត ឬកែឆ្នៃឡើងវិញទៅជាវត្ថុ ឬផលិតផលថ្មី ដែលបានចម្រាញ់ចេញពីកន្លែងចាក់សម្រាម។ |
| *វិធីសាស្ត្រគិតតាមវដ្តជីវិតវត្ថុប្រើប្រាស់* | ការវិភាគវដ្តជីវិត ពាក់ព័ន្ធទៅនឹងការពិចារណាទៅលើវដ្តជីវិតទាំងមូលនៃ ផលិតផល ឬការដំណើរការមួយ ដែលគិតតាំងពីពេលទាញយកវត្ថុធាតុដើមដំបូងរហូតទៅដល់ការកម្ទេចចោល ដើម្បីវិនិច្ឆ័យមើលភាពប៉ះពាល់ទៅលើបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ វិធីសាស្ត្រដ៏ទូលំទូលាយនេះ អាចអនុញ្ញាតឲ្យមានការសម្រេចចិត្តដែលមានមូលដ្ឋានច្បាស់លាស់តាមរយៈការវាយតម្លៃប្រកបដោយនិរន្តភាព និងភាពសន្សំសំចៃនៃជម្រើសផ្សេងៗ ពេញមួយវដ្តជីវិតទាំងមូល។ |
| *ហេដ្ឋារចនាសម្ព័ន្ធសង្គម* | ទីកន្លែង ឬបរិក្ខារដែលផ្តល់ផលប្រយោជន៍រួមដែលបម្រើសាធារណៈជន ហើយធានាថាតម្រូវការរបួធម៌សង្គម និងសុខភាពត្រូវបានបំពេញគ្រប់គ្រាន់។ |





## ការកំណត់ (បន្ត)

| | |
|---|---|
| *លំនៅឋានតម្លៃសមរម្យ* | ផ្ទះតម្លៃសមរម្យ គឺសម្តៅទៅលើលំនៅឋាន ដែលស្ថិតក្នុងតម្លៃសមស្របមួយ ដែលគ្រួសារ ឬបុគ្គលមានជីវភាពទាប ឬមធ្យមមានលទ្ធភាព ហើយផ្តល់ជាជម្រកដែលមានសុវត្ថិភាព និងសន្តិសុខ។ |
| *ការរចនាដោយគ្មានរបាំង* | ការរៀបចំបរិស្ថាន ដែលប្រើប្រាស់បានដោយមនុស្សគ្រប់គ្នាទោះបីជាមានពិការភាព ឬខ្វះខាតកាយសម្បទាក៏ដោយ។ ការរៀបចំបែបនេះ គឺចង់បំបាត់ របាំង ឬឧបសគ្គរាំងស្ទះ ហើយបង្កើនឲ្យមានការចល័ត ការទំនាក់ទំនង និងការចូលរួម ដែលជំរុញឲ្យមានបរិយាប័ន្ន ភាពឯករាជ្យ និងឱកាសស្មើរគ្នាសម្រាប់មនុស្សគ្រប់វ័យ។ |
| *សេដ្ឋកិច្ចចែករំលែក* | នៅត្រឹមកម្រិតសហគមន៍ ដែលពាក់ព័ន្ធទៅនឹងការជួយគាំទ្រទំនិញ ឬផលិតផល សេវាកម្ម និងធនធានផ្សេងៗរវាងអ្នករស់នៅក្នុងសហគមន៍ផ្ទាល់ ដែលភាគច្រើនតាមរយៈវេទិការអ៊ីធើណេត ឬប្រព័ន្ធប្រាស្រ័យទាក់ទងក្រៅផ្លូវការ។ សេដ្ឋកិច្ចបែបនេះជំរុញឲ្យមាន ការសហការ ការសន្សំសំចៃធនធាន ឬប្រើធនធានឲ្យមានប្រសិទ្ធភាព និងសុខដុមនីយកម្មសហគមន៍ ដោយទាញយកប្រយោជន៍ពីធនធានសហគមន៍-ដែលមានស្រាប់ និងជួយលើកស្ទួយការប្រាស្រ័យទុកចិត្ត ឬការជួយគ្នាទៅវិញទៅមក។ |
| *ក្រុមរចនាពហុជំនាញ* | ជាក្រុមសហការ ដែលរួមមានអ្នកមកពីវិស័យផ្សេងៗគ្នាដែលមានដូចជា ស្ថាបត្យកម្ម វិស្វកម្ម នគររូបនីយកម្ម និងវិទ្យាសាស្ត្រសង្គមដែលធ្វើការរួមគ្នា ដើម្បីដោះស្រាយឧបសគ្គក្នុងការរចនាផ្សេងៗ។ ដោយធ្វើសមាហរណកម្មជំនាញមកពីវិស័យផ្សេងៗគ្នា បែបនេះមានទិសដៅស្វែងរកដំណោះស្រាយ ដែលទូលំទូលាយ និងថ្មីប្រកបដោយភាពច្នៃប្រឌិត ដែលបានពិចារណាគ្រប់ជ្រុងជ្រោយនិងតម្រូវការផ្សេងៗ។ |
| *សិក្ខាសាលាអន្តរកម្ម* | ជាកិច្ចប្រជុំសហការមួយដែលអ្នកចូលរួមបានចូលរួមធ្វើសកម្មភាពអនុវត្តជាក់ស្តែង ធ្វើការពិភាក្សាធ្វើជាលំហាត់ដើម្បីរាវរកមើលគំនិតថ្មីៗ ដោះស្រាយបញ្ហា ឬអភិវឌ្ឍន៍ជំនាញផ្សេងៗក្នុងរបៀបមួយដែលទាមទារការចូលរួម និងមានអន្តរកម្ម ដែលជួយជំរុញភាពច្នៃប្រឌិត ការរៀន និងការធ្វើការជាក្រុម។ |
| *របៀបរស់នៅប្រកបដោយនិរន្តភាព* | ជារបៀបរស់នៅមួយដែលកាត់បន្ថយការប៉ះពាល់អវិជ្ជមានទៅដល់បរិស្ថាន ហើយទន្ទឹមនឹងនោះក៏ជួយលើកស្ទួយសមធម៌សង្គម និងវិបុលភាពសេដ្ឋកិច្ច ដែលមានលក្ខណៈរស់នៅដោយបរិភោគ ឬ ប្រើប្រាស់ដោយមានសតិយល់ដឹងក្នុងការប្រើប្រាស់ធនធាន ដែលអាចករកើតឡើងវិញបានកាត់បន្ថយកាកសំណល់ ហើយថែរក្សានូវប្រព័ន្ធអេកូឡូស៊ីសម្រាប់អ្នកជំនាន់ក្រោយៗទៀត។ |

# VI វិភាគទានពីដៃគូ B4P និងទំនាក់ទំនង

**ការសម្របសម្រួលជារួមពី B4P**

**University of Hildesheim**
Consortium Leader: Dr. Michael A. Waibel
Department of Geography
Universitätsplatz 1, 31141 Hildesheim, Germany
michael@build4people.org

**ដៃគូគ្រប់គ្រងគម្រោង**

**Cambodian Institute for Urban Studies (CIUS)**
Dr. Tep Makathy
General Director of CIUS
#89, street 315, Boeung Kak 2, Toul Kok, Phnom Penh
cambodian.cius@gmail.com

**ដៃគូប្រឹក្សាយោបល់លើការប្រើប្រាស់ប្រព័ន្ធ**

**German Sustainability Building Council (DGNB)**
Dr. Stephan Anders
Director Network and Consulting
s.anders@dgnb.de
Tübinger Straße 43
70178 Stuttgart, Germany

**ការផ្លាស់ប្តូរឥរិយាបថ**

**Otto-von-Guericke-University of Magdeburg**
Dr. Anke Blöbaum
Prof. Dr. Ellen Matthies
Department of Environmental Psychology
Universitätsplatz 2
39106 Magdeburg, Germany
anke.bloebaum@ovgu.de
ellen.matthies@ovgu.de

**Royal University of Phnom Penh (RUPP)**
Dr. Op Vanna, Department of Psychology
Dr. Sok Serey, Director of Research Office

**អគារចីរភាព**

**Technical University of Applied Sciences Lübeck**
Prof. Dr. Dirk Schwede
Chair of Department of Sustainable Building Technology
Mönkhofer Weg 239
23562 Lübeck, Germany
dirk.schwede@th-luebeck.de

**Institute of Technology of Cambodia (ITC)**
Dr. Virak Han, Faculty of Civil Engineering

**សហគមន៍ចីរភាព**

**Eble Messerschmidt Partner Architekten & Stadtplaner PartGmbB**
Dipl.-Ing. Rolf Messerschmidt
Berliner Ring 47a
72076 Tübingen, Germany
messerschmidt@eble-architektur.de

**Paññāsāstra University of Cambodia (PUC)**
Dr. Tep Makathy
Dean of Faculty of Architecture and Urban Planning (FAUP)
#89, street 315, Boeung Kak 2, Toul Kok, Phnom Penh
cambodian.cius@gmail.com

**ទីក្រុងបៃតង**

**Eberswalde University for Sustainable Development (HNEE)**
Prof. Dr. Jan-Peter Mund
Faculty of Forest and Environment
Alfred-Möller-Straße 1
16225 Eberswalde, Germany
jan-peter.mund@hnee.de

**Royal University of Agriculture (RUA)**
Dr. Sanara Hor
Dean of Faculty of Land Management and Land Administration (FLMLA)

**អាកាសធាតុ ទីក្រុង** **INKEK Institute for Climate and Energy Concepts GMBH**

Prof. Dr. Lutz Katzschner
Dr. Janalisa Hahne
Dipl.-Ing. Sebastian Kupski
Schillerstraße 50
34253 Lohfelden, Germany
info@inkek.de

**Royal University of Phnom Penh (RUPP)**
Dr. Chhinh Nyda
Dr. Se Bunleng
Dr. Daniel Choi

**បរិវត្តកម្មទីក្រុង ដោយចីរភាព** **University of Hildesheim**
Dr. Michael Waibel
Department of Geography
Universitätsplatz 1
31141 Hildesheim, Germany
michael@build4people.org

**Royal University of Phnom Penh (RUPP)**
Dr. Seak Sophat
Dr. Sothun Nop

**SMMR** **Sustainable Mobility for Metropolitan Regions in ASEAN**
Dipl.-Ing Sovanarith Sieng
Ministry of Public Works and Transport
Street 598 (H.E. Chea Sophara Street), Sangkat Chrang Chamres 2,
Khan Russey Keo Phnom Penh, Cambodia
sovan@smmr.asia





# គោលការណ៍ណែនាំ នៃគម្រោង B4P សម្រាប់ស្វែងយល់បន្ត៖

០២-១ សេចក្ដីណែនាំអំពីការរចនាទីក្រុងបែបសមាហរណកម្ម

០២-២ សេចក្ដីណែនាំអំពីហេដ្ឋារចនាសម្ព័ន្ធបៃតង ខៀវ

០២-៣ សេចក្ដីណែនាំអំពីការចល័តប្រកបដោយចីរភាព

០២-៤ សេចក្ដីណែនាំអំពីការការពារអាកាសធាតុ និងលំហូរថាមពល

០២-៥ សេចក្ដីណែនាំអំពីបរិយាប័ន្នសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន

០២-៦ សេចក្ដីណែនាំអំពីអភិបាលកិច្ច និងការចូលរួម

**ស្កេនខ្ញុំ! ...**
.... ដើម្បីទាញយក
TOOLBOX ឯកសារផ្សេងទៀត
ដែលរៀបចំឡើងដោយ B4P!

# VII ឯកសារយោង


Bott, H., Grassl, G. C., & Anders, S. (2019). Sustainable Urban Planning: Vibrant Neighbourhoods – Smart Cities – Resilience = Nachhaltige Stadtplanung: lebendige Quartiere- Smart cities- Resilienz (2nd edition). Detail Business Information GmbH.

DGNB. (2020). DGNB System Districs Criteria Set. Deutsche Gesellschaft für Nachhaltiges Bauen (German Sustainable Buildings Council) – DGNB e.V., Tübinger Straße 43, 70178 Stuttgart.

European Comission, & European Comission (Eds.). (2019). The economic benefits of the Natura 2000 network: Synthesis report. Publ. Off. of the Europ. Union.

Global Green Growth Institute. (2019). Phnom Penh Green City Strategic Plan 2016—2025. Global Green Growth Institute.

Kol, L., & Brugman, J. (2022). Affordable Housing Policy in Cambodia and Southeast Asia (p. 39). Equitable Cambodia. https://equitablecambodia.org/website/article/3-2474.html

Messerschmidt, R., & Gaffron, P. (Eds.). (2005). Ecocity. Book 1: A better place to live / with contr. from: Rolf Messerschmidt. Facultas.

Molika, H. (2022). National Housing Policies in Cambodia and Thailand: A Comparative Analysis [Policy Brief]. Asian Vision Institute.

Slow progress on affordable housing. (2018, April 13). The Phnom Penh Post. https://www.phnompenhpost.com/post-property/slow-progress-affordable-housing

United Nations Environment Programme & Cambodia. (2009). Cambodia environment outlook. Ministry of Environment.

UN. General Assembly (66th sess. : 2011-2012). President. (2012, July 24). The future we want: Draft resolution / submitted by the President of the General Assembly. A/RES/66/288.

World Economic Forum. (2016, April). Global Challenge Initiative Economic Growth and Social Inclusion.



### អ្នកនិពន្ធ
*Nuria Roig, Eble Messerschmidt Partner*
*Rolf Messerschmidt, Eble Messerschmidt Partner*
*Stephan Anders, German Sustainability Building Council (DGNB)*

### អ្នកត្រួតពិនិត្យ
*Michael Waibel, Department Geography, University of Hildesheim*
*Tep Makathy, Cambodian Institue for Urban Studies (CIUS)*
*Dean of Faculty of Architecture and Urban Planning at Paññāsāstra University of Cambodia*
*Martin Aerne, Director|Chief Architect at Aerne Architects & Associates Co.*
*Lecturer at Royal University of Fine Arts (RUFA)*

### សម្រួលជាខេមរភាសា
*លោកស្រី គល់ សុជាតា*
*InDesignដោយ៖ ហៃ ប៊ុនហុង និងហេង វឌ្ឍន:*



*Unless otherwise stated, the Build4People projects hold the copyrights for the illustrations.*



### គោលគំនិតនិងការរៀបចំក្រាហ្វិក

EBLE MESSERSCHMIDT PARTNER
Architekten und Stadtplaner PartGmbB

### ថ្លែងអំណរគុណ

*មូលនិធិនៃគម្រោង **Build4People** ត្រូវបានផ្តល់ឲ្យដោយក្រសួងស្រាវជ្រាវ បច្ចេកវិទ្យា និងអវកាសនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (BMFTR)។*

*ការបោះពុម្ពនេះ ត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌនៃគម្រោង **Build4People** ក្រោមកិច្ចសហការជាមួយដៃគូ **Build4People** ទាំងអស់។*

### បោះពុម្ពផ្សាយ និងលេខទំនាក់ទំនង



University of Hildesheim-
Department of Geography
Universitätsplatz 1
31141 Hildesheim, Germany

Dr. Michael Waibel
michael@build4people.org

HTTPS://BUILD4PEOPLE.ORG/

# BUILD4PEOPLE
## លក្ខណៈវិនិច្ឆ័យ និងទិដ្ឋភាព ទូទៅនៃសេចក្តីណែនាំលើការ រចនាទីក្រុងបែបសមាហរណកម្ម

ស្កេនខ្ញុំ! ...
.... ដើម្បីទាញយក
TOOLBOX ឯកសារផ្សេងទៀត
ដែលរៀបចំឡើងដោយ B4P!



















